**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៨៥.........សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាចវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញប្រកាសលេខ ២០៣ ប្រក សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង
- បានឃើញប្រកាសលេខ ៣២៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២ ស្តីពីទម្រង់និងមាតិកាថវិកាឃុំ សង្កាត់ និងត្រូវបានកែសម្រួលដោយប្រកាសលេខ ៨៨១ សហវ.ហម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ និងប្រកាសលេខ ២០២ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមនូវគំរូតារាងរបាយការណ៍ មាតិកាថវិកា មាតិកាគណនីឃុំ សង្កាត់
- បានឃើញប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញប្រកាសលេខ ១៤០៩ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត ក្រុង និងស្រុក ខណ្ឌ
- បានឃើញប្រកាសលេខ ២៨៥ សហវ.ប្រក.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :** ត្រូវបានដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលចែកជាចំណាត់ថ្នាក់ចំណូល ចំណាយ និងត្រូវបានបែងចែក ជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន:</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន "ដើម្បីអនុវត្ត"
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រដ្ឋបាលថ្នាក់ក្រោមជាតិ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥... សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | | **សរុបរួមចំណូលថវិកា (ក+ខ)** | សរុបចំណូលជាចរន្ត និងសរុបចំណូលមូលធន។ | ✓ | ✓ | ✓ | ✓ |
| | | | **ក.សរុបចំណូលចរន្ត (ក្រុមទី១ + ក្រុមទី២)** | ចំណូលដែលត្រូវប្រមូលជាប្រចាំ។ ចំណូលនេះរួមមានចំណូលពិត និងចំណូលតាមដីកា។ | ✓ | ✓ | ✓ | ✓ |
| | | | **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | ចំណូលជាសាច់ប្រាក់ជាក់ស្តែង។ ចំណូលនេះរួមមានចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី១ : ចំណូលសារពើពន្ធ** | ចំណូលសារពើពន្ធគឺជាពន្ធអាករ និងសិទ្ធិដែលត្រូវបានបង្វែរជាកាតព្វកិច្ចទៅឲ្យរដ្ឋ។ ចំណូលនេះរួមមានៈ ចំណូលសារពើពន្ធក្នុងប្រទេស និងចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។ | ✓ | ✓ | ✓ | ✓ |
| 70 | | | **ចំណូលសារពើពន្ធក្នុងស្រុក** | កត់ត្រាចំណូលទទួលបានពីពន្ធដារ និងពន្ធគយក្នុងប្រទេស។ | ✓ | ✓ | ✓ | |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណេញ) | ចំណូលមកពីការបង់ពន្ធលើផលទុន ប្រាក់ចំណេញរបស់រូបវន្តបុគ្គល និងនីតិបុគ្គល។ | ✓ | | | |
| | | 70011 | ពន្ធលើប្រាក់ចំណេញ (រូបវន្តបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសនិងក្រុមហ៊ុន (រូបវន្តបុគ្គល)។ | ✓ | | | |
| | | 70012 | ពន្ធលើប្រាក់ចំណេញ (នីតិបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសនិងក្រុមហ៊ុន (នីតិបុគ្គល)។ | ✓ | | | |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | ចំណូលបានមកពីការបង់ពន្ធប្រាក់បៀវត្សដោយបុគ្គលិករដ្ឋ ឬ ឯកជន ដែលជាប់កាតព្វកិច្ចបង់ពន្ធ។ | ✓ | | | |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើឈ្នួលផ្ទះ ដីធ្លី ផ្ទះសម្បែង និងពីការជួលគ្រឿងយន្ត (រូបវន្តបុគ្គល)។ | ✓ | | | |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើឈ្នួលផ្ទះ ដីធ្លី ផ្ទះសម្បែង និងពីការជួលគ្រឿងយន្ត (នីតិបុគ្គល)។ | ✓ | | | |
| | 7002 | | ពន្ធប្រយោល | ចំណូលទទួលបានពីការបង់អាករលើផលរបរ និងអាករលើតម្លៃបន្ថែម។ អាករនេះអាចត្រូវបានប្រមូលគ្រប់រូបភាពនៃ ដំណើរផលិតកម្ម ការចែកចាយទំនិញឬសេវា ដែលផលិតនៅក្នុងប្រទេស ឬ នាំចូលពីបរទេស ។ | ✓ | | | |
| | | 70021 | អាករលើផលរបរ | ចំណូលបានមកពីការបង់អាករលើផលរបររបស់សហគ្រាសនៅក្នុងរបបម៉ៅការ។ | ✓ | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 70022 | អាករលើតម្លៃបន្ថែម | ចំណូលបានមកពីការបង់អាករបន្ថែមលើតម្លៃទំនិញឬសេវាកម្មផ្សេងៗ ដោយសហគ្រាសដែលផលិតទំនិញ ឬ ចែកចាយទំនិញ និងសេវាកម្មទាំងនោះនៅក្នុងប្រទេស។ | ✓ | | | |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល ( សហគ្រាសប្រេងឥន្ធនៈ ) | ចំណូលបានមកពីការបង់អាករបន្ថែម លើតម្លៃប្រេងឥន្ធនៈដែលបាននាំចូល។ | ✓ | | | |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល ( សហគ្រាសផ្សេងៗទៀត ) | ចំណូលបានមកពីការបង់អាករបន្ថែមលើតម្លៃទំនិញ ឬ សេវាកម្មផ្សេងៗ ក្រៅពីប្រេងឥន្ធនៈដែលបាននាំចូល។ | ✓ | | | |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល ទំនិញជាសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) | ចំណូលប្រភេទនេះបានមកពីអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញជាសម្ភារៈកសិកម្ម ( ការកត់ត្រាជាចំណូលថវិកាក្នុងអនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ )។ | ✓ | | | |
| | 7003 | | អាករពិសេស | ចំណូលទទួលបានពីការបង់អាករពិសេសលើទំនិញនិងសេវាមួយចំនួន ដែលបានកំណត់ទាំងរបបផ្ទៃក្នុង និងរបបនាំចូល។ អាករពិសេសនេះ អាចត្រូវបានប្រមូលតាមកំរិតណាមួយនៃផលិតកម្ម ឬការចែកចាយ និងត្រូវបានគណនាតាមរយៈតម្លៃ ទំងន់ កំលាំង ឬ គុណភាពនៃផលិតផល ដូចជាពន្ធលើស្ករ បារី ថ្នាំជក់ ស្រា ប្រេងឥន្ធនៈ អាករលើអគ្គិសនី ឬ ហ្គាស...។ល។ | ✓ | ✓ | ✓ | |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | ចំណូលបានមកពីការបង់អាករពិសេសលើទំនិញ ដែលផលិតឬចែកចាយនៅក្នុងប្រទេស។ | ✓ | | | |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | ចំណូលបានមកពីការបង់អាករពិសេសលើប្រេងឥន្ធនៈដែលបាននាំចូល។ | ✓ | | | |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | ចំណូលបានមកពីការបង់អាករពិសេសលើទំនិញផ្សេងៗទៀត ក្រៅពីប្រេងឥន្ធនៈដែលបាននាំចូល ដូចជាអាករពិសេស លើការនាំចូលស្រា បារី ...។ល។ | ✓ | | | |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | ចំណូលបានមកពីការបង់អាករពិសេសលើសេវាមួយចំនួននៅក្នុងប្រទេស។ | ✓ | | | |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | ចំណូលទទួលបានមកពីការបង់ពន្ធលើការលក់ស្រា ស្រាបៀ និងបារី ដែលផលិតមកពីបរទេស និងផលិតផលក្នុងស្រុក នៅក្នុងមណ្ឌលដែនដីរាជធានី-ខេត្ត សម្រាប់ចំណាយការបំភ្លឺសាធារណៈ។ | | ✓ | ✓ | |
| | | 70038 | ផ្សេងៗ | គណនីនេះរក្សាទុកសម្រាប់ករណីមានប្រភពចំណូលថ្មី ដែលតម្រូវឲ្យបង្កើតគណនីចំណូលដែលទទួលបានពីការអាករពិសេសផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | | | |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 7004 | | អាករលើសេវាដែលបានកំណត់ | ចំណូលទទួលបានពីការបង់អាករលើសេវាដែលបានកំណត់ដូចជា អាករលើកាស៊ីណូ អាករលើឆ្នោត អាករលើល្បែងភ្នាល់ផ្សេងៗ អាករលើអាកាសយានដ្ឋាន អាករលើការស្នាក់នៅ និងពន្ធសត្តឃាត។ អាករនេះត្រូវបានគណនាលើលាភការនៃសេវាពិសេស និងអាករលើល្បែងចៃដន្យ ល្បែងភ្នាល់ និង ការទទួលបាន ពីកាស៊ីណូ ...។ល។ | ✓ | ✓ | ✓ | |
| | | 70041 | អាករលើកាស៊ីណូ | ចំណូលបានមកពីការបង់អាករលើកាស៊ីណូ ចំណូលពីស្លុតម៉ាស៊ីន។ | ✓ | | | |
| | | 70042 | អាករលើឆ្នោត | ចំណូលបានមកពីការបង់អាករលើឆ្នោត។ | ✓ | | | |
| | | 70043 | អាករលើល្បែងភ្នាល់ផ្សេងៗ | ចំណូលបានមកពីការបង់អាករលើល្បែងភ្នាល់ផ្សេងៗ ដូចជាការភ្នាល់បាល់ ...។ល។ | ✓ | | | |
| | | 70044 | អាករអាកាសយានដ្ឋាន | ចំណូលបានមកពីការបង់អាករអាកាសយានដ្ឋាន។ | ✓ | | | |
| | | 70045 | អាករលើការស្នាក់នៅ | ចំណូលទទួលបានមកពីការបង់អាករលើការស្នាក់នៅតាមសណ្ឋាគារ អាផាតមិន ម៉ូតែល ផ្ទះសំណាក់ និងប៊ឹងកាឡូ។ | | ✓ | ✓ | |
| | | 70046 | ពន្ធសត្តឃាត | ចំណូលបានមកពីការបង់ពន្ធលើការធ្វើអាជីវកម្មពិឃាដសត្វ ដូចជា ជ្រូក គោ ក្របី តាមសត្តឃាតដ្ឋាន។ | | ✓ | ✓ | |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព | ចំណូលទទួលបានពីការបង់អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាព ដូចជា:ចំណូលទទួលបានពីការ ផ្តល់អាជ្ញាប័ណ្ណនាំចេញ និងអាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ពន្ធប៉ាតង់ និងពន្ធមធ្យោបាយដឹកជញ្ជូន។ | ✓ | ✓ | ✓ | |
| | | 70051 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | ចំណូលបានមកពីការផ្តល់អាជ្ញាប័ណ្ណនាំចេញគ្រប់បែបយ៉ាង។ | ✓ | | | |
| | | 70052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | ចំណូលបានមកពីការផ្តល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ដូចជាអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ អាជ្ញាប័ណ្ណឆ្នោត អាជ្ញាប័ណ្ណទេសចរណ៍...។ អនុគណនីនេះកត់ត្រាផងដែរនូវពន្ធដែលបង់ដោយអ្នកធ្វើសម្បទានដែលជាអ្នកធ្វើវិនិយោគដោយខ្លួនឯង។ | ✓ | | | |
| | | 70053 | ពន្ធប៉ាតង់ | ចំណូលបានមកពីពន្ធប៉ាតង់ចំពោះសហគ្រាសដែលប្រកបអាជីវកម្ម។ | | ✓ | ✓ | |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ | ចំណូលបានមកពីការបង់ពន្ធមធ្យោបាយដឹកជញ្ជូនដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានយន្តគ្រប់ប្រភេទដែល ធ្វើចរាចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ | | ✓ | ✓ | |
| | 7006 | | ពន្ធប្រថាប់ត្រា | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា។ | | ✓ | ✓ | |

## ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដីធ្លី ឬ ការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។ | | ✓ | ✓ | |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬ យានយន្តគ្រប់ប្រភេទ។ | | ✓ | ✓ | |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរ | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ០,១% នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។ | | ✓ | ✓ | |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវា | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវាដែលប្រើប្រាស់ថវិការដ្ឋ។ | | ✓ | ✓ | |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្តិ | ចំណូលបានមកពីការបង់ពន្ធប្រថាប់ត្រា ១ ០០០ ០០០ រៀល (មួយលានរៀល) ចំពោះលិខិតមានលក្ខណៈគតិយុត្តិ ជាអាទិ៍លិខិតស្ដីពីការបង្កើតក្រុមហ៊ុន លិខិតស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្ដីពីការបិទក្រុមហ៊ុន។ | | ✓ | ✓ | |
| | 7007 | | ពន្ធលើអចលនទ្រព្យ | ចំណូលបានមកពីការបង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់។ | | ✓ | ✓ | |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើអចលនទ្រព្យរួមមានដី ផ្ទះ អាគារ និងសំណង់ផ្សេងៗដែលគ្រប់គ្រងដោយរូបវន្តបុគ្គល។ | | ✓ | ✓ | |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | ចំណូលបានមកពីការបង់ពន្ធលើអចលនទ្រព្យរួមមាន ដី ផ្ទះ អាគារ និងសំណង់ផ្សេងៗដែលគ្រប់គ្រងដោយនីតិបុគ្គល។ | | ✓ | ✓ | |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ចំណូលបានមកពីការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលទុកដីឲ្យនៅទំនេរមិនធ្វើផលិតកម្ម ឬទិញដីទុក។ | | ✓ | ✓ | |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | ចំណូលទទួលបានពីពន្ធតែមប្រ៍ និងចំណូលបានមកពីការពិន័យលើភាពយឺតយ៉ាវនិងកំហុសនៃការបង់ពន្ធ។ | ✓ | | | |
| | | 70081 | ពន្ធតែមប្រ៍ | ចំណូលបានមកពីការបង់ពន្ធតែមប្រ៍តាមកិច្ចសន្យា ។ | ✓ | | | |
| | | 70082 | ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ | ចំណូលបានមកពីការពិន័យលើភាពយឺតយ៉ាវ និងកំហុសនៃការបង់ពន្ធ។ | ✓ | | | |
| | | 70083 | ចំណូលលក់ឯកសារពន្ធ | ចំណូលពីការលក់ឯកសារពន្ធ។ | ✓ | | | |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| 71 | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | កត់ត្រាចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការនាំចូល និងការនាំចេញ។ | ✓ | | | |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | ចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការនាំចូល។ | ✓ | | | |
| | | 71001 | ពន្ធគយពីការនាំចូល | ចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលទំនិញផ្សេងៗ លើកលែងតែការនាំចូលប្រេងឥន្ធនៈ។ | ✓ | | | |
| | | 71002 | កម្រៃពីការងារគយ | ចំណូលទទួលបានពីការយកកម្រៃផ្សេងៗក្នុងការនាំចូល ដូចជាការនាំចូលទំនិញសម្រាប់លក់ក្នុងអាគារលក់ទំនិញរួចពន្ធ ការនាំចូលទំនិញឆ្លងកាត់ ការស្តុកទំនិញក្នុងឃ្លាំងឬទីលានហួសកាលកំណត់ កម្រៃបំពេញបែបបទគយ កម្រៃត្រួតពិនិត្យទំនិញតាមរយៈម៉ាស៊ីនស្កេន និងកម្រៃផ្សេងៗទៀត ដែលពុំមែនជាពន្ធ ឬ អាករ។ | ✓ | | | |
| | | 71003 | ពន្ធគយលើផលិតផលតេលសិលា | ចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលប្រេងឥន្ធនៈ។ | ✓ | | | |
| | | 71004 | អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | ចំណូលទទួលបានពីការបង់អាករបន្ថែមចំនួន ០,០២ ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងសាំង និង ០,០៤ ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងម៉ាស៊ូត ហើយចំណូលនេះប្រើប្រាស់សម្រាប់ថែទាំផ្លូវថ្នល់ និងគោលនយោបាយធារាសាស្ត្រ។ | ✓ | | | |
| | | 71005 | ផលនៃការលក់ផ្នែកគយ | ចំណូលទទួលបានពីការលក់ទំនិញផ្សេងៗ(ល្មើសច្បាប់គយ) ដែលអង្គភាពគយរឹបអូសបាន។ | ✓ | | | |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | ចំណូលទទួលបានពីការបង់ពិន័យផ្សេងៗលើការនាំចូល។ | ✓ | | | |
| | | 71007 | ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) | ចំណូលប្រភេទនេះបានមកលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ការកត់ត្រាជាចំណូលថវិកាក្នុងអនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ)។ | ✓ | | | |
| | | 71008 | ផ្សេងៗ | គណនីនេះរក្សាទុកសម្រាប់ករណីមានប្រភពចំណូលថ្មី ដែលតម្រូវឲ្យបង្កើតគណនីចំណូលដែលទទួលបានពីការបង់ពន្ធ ឬ អាករលើការនាំចូលផ្សេងទៀតក្រៅពីអនុគណនីខាងលើ។ | ✓ | | | |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | ចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការនាំចេញ។ | ✓ | | | |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៤៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 71011 | អាករលើការនាំចេញឈើ | ចំណូលទទួលបានពីការបង់អាករ លើការនាំចេញឈើគ្រប់ប្រភេទ។ | ✓ | | | |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញកៅស៊ូ។ | ✓ | | | |
| | | 71013 | អាករលើការនាំចេញផលិតផលគេលសិលា | ចំណូលទទួលបានពីការបង់អាករលើការនាំចេញផលិតផលគេលសិលា។ | ✓ | | | |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញទំនិញផ្សេងៗ ក្រៅពីឈើ កៅស៊ូ និងផលិតផលគេលសិលា។ | ✓ | | | |
| | | 71015 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ចំណូលទទួលបានពីការផ្ដល់កូតា និង អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ ស្បែកជើង ...។ល។ | ✓ | | | |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | ចំណូលទទួលបានពីការពិន័យផ្សេងៗលើការនាំចេញដែលមិនគោរពតាមបទដ្ឋាន។ | ✓ | | | |
| | | 71018 | ផ្សេងៗ | គណនីនេះរក្សាទុកសម្រាប់ករណីមានប្រភពចំណូលថ្មី ដែលតម្រូវឱ្យបង្កើតគណនីចំណូលដែលទទួលបានពីការបង់ពន្ធ ឬ អាករលើការនាំចេញផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | | | |
| | | | **ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ** | ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា ផលពីការដាក់ពិន័យ និងការដាក់ ទណ្ឌកម្ម ការឧបត្ថម្ភ អំណោយ ផលហិរញ្ញវត្ថុ និងផលផ្សេងៗ និងផលពិសេស។ | ✓ | ✓ | ✓ | ✓ |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | ចំណូលទទួលបានពីការជួល និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។ | ✓ | ✓ | ✓ | |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជាការជួលឡូត៍នេសាទ ការជួលដីព្រៃឈើ ការជួលដែនទឹកសំរាប់ធ្វើ អាជីវកម្មប្រេងកាត ការជួលដីសំរាប់ករកម្រៃ និងការជួលដីធ្លីផ្សេងៗទៀត។ | ✓ | ✓ | ✓ | |
| | | 72001 | សម្បទាននេសាទ | ចំណូលទទួលបានពីការជួលឡូត៍នេសាទ។ | ✓ | | | |
| | | 72002 | សម្បទានព្រៃឈើ | ចំណូលទទួលបានពីការធ្វើសម្បទានព្រៃឈើ ដូចជាចំណូលពីការលក់ឈើឈរ អនុផលព្រៃឈើ និងចំណូលពីការលក់ ឈើខុសច្បាប់ដែលរឹបអូសបាន។ | ✓ | | | |
| | | 72003 | សម្បទានពីប្រេងកាត | ចំណូលទទួលបានពីការជួលដី ឬ ដែនទឹកដែលមានប្រេងកាត ទៅឲ្យឯកជនដើម្បីធ្វើអាជីវកម្មបូមប្រេងកាត។ | ✓ | | | |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ [illegible] ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 72004 | សម្បទានរ៉ែ | ចំណូលទទួលបានពីការជួលផ្ទៃដីសំរាប់ដំណាក់កាលសិក្សាស្រាវជ្រាវរុករករ៉ែ និងជួលដី ជំរករ៉ែ និងទីតាំងអាជីវកម្មក្នុង ដំណាក់កាលធ្វើអាជីវកម្មរ៉ែ និងចំណូលទទួលបានពីសួយសារ និងភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្មរ៉ែ។ ចំណូល ទទួលបានពីការធ្វើអាជីវកម្មវត្ថុធាតុដើមសំណង់ដូចជាដី ខ្សាច់ ថ្ម គ្រួស រ៉ែបុកស៊ីត រ៉ែដែក ហ្គាស ឧស្ម័ន ធ្យូងថ្ម ត្បូង...។ល។ | ✓ | ✓ | ✓ | |
| | | 72005 | ការជួលដីទំនេរ (មានតែដី) | ចំណូលពីការជួលដីសំរាប់សង់ទីផ្សារលក់ដូរ និងសំណង់ចាស់ទ្រុឌទ្រោមផ្សេងទៀត ដែលមិនអាចប្រើបាន។ | ✓ | ✓ | ✓ | |
| | | 72006 | ចំណូលពីចំណតរថយន្ត | ចំណូលទទួលបានពីរថយន្តធ្វើអាជីវកម្មប្រើប្រាស់ចំណតដែលរដ្ឋបានកំណត់។ | | ✓ | ✓ | |
| | | 72007 | ចំណូលពីចំណតជលយាន | ចំណូលទទួលបានពីទូក កាណូត កប៉ាល់ ធ្វើអាជីវកម្មប្រើប្រាស់កំពង់ផែ ចំណតជើងទឹក ដែលរដ្ឋបានកំណត់។ | | ✓ | ✓ | |
| | | 72008 | ផលនៃការជួលដីធ្លីផ្សេងៗ | ចំណូលពីការជួលដីធ្លីផ្សេងៗទៀតដែលមិនមាននៅក្នុងអនុគណនីខាងលើ។ | ✓ | ✓ | ✓ | |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | កត់ត្រាចំណូលទទួលបានពីសហគ្រាសសាធារណៈ ដូចជាចំនួនលើសនៃទុនចល័ត ប្រាក់ចំណេញ ការបង់ប្រាក់រំលស់ និងទុនផ្សេងៗទៀត។ | ✓ | | | |
| | | 72011 | ការដកចំនួនលើសនៃទុនចល័ត | ចំណូលទទួលបានពីការបង់មកវិញនូវទុនចល័តដែលលើសពីតម្រូវការរបស់សហគ្រាសសាធារណៈ។ | ✓ | | | |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | ចំណូលទទួលបានពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈ ក្រោយការិយបរិច្ឆេទបិទបញ្ជីប្រចាំឆ្នាំ ដូចជា ប្រាក់ចំណេញរបស់ក្រុមហ៊ុនកៅស៊ូកម្ពុជា កំពង់ផែស្វយ័ត កាំសាប អគ្គីសនីកម្ពុជា រដ្ឋាករទឹក...។ល។ | ✓ | | | |
| | | 72013 | ការបង់ប្រាក់រំលស់ (អចលនវត្ថុ) | ចំណូលទទួលបានពីការបង់ប្រាក់រំលស់របស់សហគ្រាសសាធារណៈ។ | ✓ | | | |
| | | 72014 | ប្រាក់ធានារ៉ាប់រងសង្គម | ចំណូលប្រភេទនេះបានមកពីការបង់របស់សហគ្រាសសាធារណៈ សំរាប់ផលប៉ះបាល់ទៅលើសុខភាពបុគ្គលិក កម្មករ...។ល។ | ✓ | | | |
| | | 72018 | ផលទុនផ្សេងៗពីសហគ្រាសសាធារណៈ | ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈក្រៅពីអនុគណនីខាងលើ ។ | ✓ | | | |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | កត់ត្រាចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិតូចតាចក្រៅពីដីធ្លី និងអាគារ ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិ និងចំណូលទទួលបានពីការផ្តល់សេវាដោយរដ្ឋ។ | ✓ | ✓ | ✓ | ✓ |

## ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៥៥... សហវ.ប្រក ចុះថ្ងៃទី២៦ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ(រកចំណេញ) | ចំណូលទទួលបានពីស្ថាប័នរដ្ឋ និងសហគ្រាសសាធារណៈក្នុងការផ្តល់សេវា និងការផ្តល់សិទ្ធិ។ | ✓ | ✓ | | |
| | | 73001 | ផលទុនរបស់អាកាសចរណ៍ស៊ីវិល | ចំណូលទទួលបានពីប្រតិបត្តិការនៃក្រុមហ៊ុនអាកាសចរនៅកម្ពុជា និងសិទ្ធិនៃការហោះហើរឆ្លងកាត់លំហអាកាសកម្ពុជា។ | ✓ | | | |
| | | 73002 | ផលទុននៃសកម្មភាពភាពយន្ត | ចំណូលទទួលបានពីការអនុញ្ញាតឲ្យថតខ្សែភាពយន្ត។ | ✓ | | | |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ។ ចំណូលទទួលបានពីការចូល ទស្សនាកំសាន្តរមណីយដ្ឋានធម្មជាតិ ការជួលស្តង់សំរាប់ពិពណ៌ ជួលកន្លែងលក់ ជួលសំលៀកបំពាក់សំរាប់ភ្ញៀវទេសចរណ៍...។ល។ | ✓ | | | |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ ព្រះបរមរាជវាំង ការអនុញ្ញាតឲ្យថតចំលងបទចំរៀង។ | ✓ | | | |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំណូលទទួលបានពីការផ្តល់សេវាផ្នែកបញ្ញើសំបុត្រ ឬឥវ៉ាន់ និងការប្រើប្រាស់សេវាទូរគមនាគមន៍។ | ✓ | | | |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | ចំណូលទទួលបានពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ និងវិទ្យុ។ | ✓ | | | |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | ចំណូលទទួលបានពីចំណែកគិតជាភាគរយនៃផលចំណេញលើសកម្មភាពផលិតទឹកស្អាត និងអគ្គិសនីបង់ដោយរដ្ឋាករ ទឹកនិងផលពីសេវាផ្គត់ផ្គង់ទឹកផ្សេងទៀត និងពីអ្នកផ្គត់ផ្គង់អគ្គិសនី។ | ✓ | | | |
| | | 73008 | ផលទុនផ្សេងៗទៀត | ចំណូលទទួលបានពីផលទុនផ្សេងៗទៀតរបស់ស្ថាប័នរដ្ឋ និងសហគ្រាសសាធារណៈ ក្រៅពីអនុគណនីខាងលើ ដូចជាចំណូល ២% លើផលិតផលស្រាបៀអង្គរ ចំណូលពីពាណិជ្ជសញ្ញា ចំណូលពីសេវាសោតទស្សន៍ ចំណូលពីការ លក់ផលិតផលកសិកម្មមាន ស្រូវពូជ ពោត សណ្តែក ពូជសត្វ កូនរុក្ខជាតិ។ ចំណូលទទួលបានពីភាគទានលូទឹកស្អុយ ១០% លើថ្លៃប្រើប្រាស់ទឹកស្អាត បង់ ដោយរដ្ឋាករទឹកស្វយ័ត។ | ✓ | ✓ | | |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ។ | ✓ | ✓ | ✓ | ✓ |
| | | 73011 | ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | ចំណូលទទួលបានពីការលក់សម្ភារៈបរិក្ខារចាស់ៗដូចជា រថយន្ត ម៉ូតូ កំព្យូទ័រ តុ ទូ ...។ល។ | ✓ | ✓ | ✓ | ✓ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | ចំណូលទទួលបានពីការលក់សៀវភៅការងារ ការលក់ឯកសារផ្សេងៗ និងលតាប័ត្រ របស់ពន្ធដារនិងគយ ចំណូលពីការចេញលិខិតបញ្ជាក់ពាក់ព័ន្ធបទល្មើសផ្សេងៗ ចំណូលពីការលក់ឯកសារដេញថ្លៃ ...។ល។ | ✓ | | | |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី និងសត្វពាហនៈ។ | ✓ | | | |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | ចំណូលទទួលបានពីស្ថាប័នរដ្ឋក្នុងការចេញលិខិតអនុញ្ញាតបើកបរ លិខិតឆ្លងដែន សោហ៊ុយយុត្តិធម៌ និងចំណូលពីការ ចុះបញ្ជីគណៈបក្សនយោបាយ។ ចំណូលសំរាប់ទំរង់ការរដ្ឋបាលនិងការអនុញ្ញាតរដ្ឋបាល របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំណត់ដោយច្បាប់។ | ✓ | ✓ | ✓ | ✓ |
| | | 73021 | អាករស្ថានទូត ( លិខិតឆ្លងដែននិងទិដ្ឋាការ ) | ចំណូលទទួលបានពីការផ្តល់ទិដ្ឋាការ និងការចេញលិខិតឆ្លងដែន។ | ✓ | | | |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | ផលពីការចុះបញ្ជីគណបក្សនយោបាយ។ | ✓ | | | |
| | | 73023 | ផលពីការបង្កើតសហគ្រាស | ចំណូលទទួលបានពីការចុះបញ្ជីធ្វើពាណិជ្ជកម្ម ផ្លាកសញ្ញា ចុះបញ្ជីឈ្មោះអ្នកទទួលការសាងសង់លទ្ធកម្ម ច្បាប់អាជីវកម្មយានយន្ត...។ល។ | ✓ | | | |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | ចំណូលទទួលបានពីភាគទានដែលបង់ដោយសិស្សដើម្បីទទួលបានសិទ្ធិប្រឡង។ | ✓ | | | |
| | | 73025 | ផលពីការលក់ស្លាកលេខ | ចំណូលទទួលបានពីសេវាផ្តល់ស្លាកលេខ បច្ចេកទេសយានយន្ត។ | ✓ | | | |
| | | 73026 | ចំណូលពីប្រដាប់ក្តី | ចំណូលទទួលបានពីការជំនុំជំរះក្តី ( ពន្ធហ្មឹង ពន្ធសមមាត្រ ពន្ធបណ្តឹងសារទុក្ខ ពន្ធឧទ្ធរណ៍ ពន្ធសកម្មភាពតុលាការ ពាក្យសុំរូបមន្តសាលដីកា និងពាក្យសុំអន្តរាគមន៍.... )។ | ✓ | | | |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន និងសេវាត្រួតពិនិត្យអនាម័យសត្វ | ចំណូលទទួលបានពីការត្រួតពិនិត្យគុណភាពទំនិញ គុណភាពឱសថ កាសែត និងភាពយន្ត និងការគោរពបទដ្ឋាន និង ចំណូលពីការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការឃ្លាំមើលការអនុវត្តន៍គំរោង។ ចំណូលទទួល បានពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វធ្វើចរាចរ និងនៅសត្តឃាតដ្ឋាន ...។ល។ | ✓ | ✓ | ✓ | |
| | | 73028 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទំរង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | ចំណូលទទួលបានពីការបញ្ជាក់លើហត្ថលេខា លិខិតចំលងច្បាប់ដើម វិញ្ញាបនប័ត្រ លិខិតផ្សេងៗ និងចំណូលពីការ អនុញ្ញាតផ្សេងៗ ដល់អ្នកប្រើប្រាស់ដែលបានធានាអះអាងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ និងចំណូលពីការគ្រប់គ្រងរដ្ឋបាលផ្សេងៗ។ | | ✓ | ✓ | ✓ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈ ការជួលសម្ភារៈ មធ្យោបាយដឹកជញ្ជូន ការជួលអចលនវត្ថុផ្សេងៗ ក្រៅពីដីធ្លី។ | ✓ | ✓ | ✓ | ✓ |
| | | 73031 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្ដាល | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈនៅរដ្ឋបាលកណ្ដាល។ | ✓ | | | |
| | | 73032 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់ខេត្ត (មន្ទីរជំនាញ) | ចំណូលទទួលបានពីការជួលសហគ្រាសសាធារណៈនៅតាមរាជធានី ខេត្ត។ | ✓ | | | |
| | | 73033 | ការជួលសម្ភារៈ និងមធ្យោបាយដឹកជញ្ជូន | ចំណូលទទួលបានពីការជួលសម្ភារៈ និងមធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ។ | ✓ | | | |
| | | 73034 | ការជួលអចលនវត្ថុ (អសង្ហារឹម) | ចំណូលទទួលបានពីការជួលអាគារ ដូចជា រោងកុន ឃ្លាំង រោងមហោស្រព រោងជាង ...។ ចំណូលទទួលបានពីការជួល ទ្រព្យសម្បត្តិអចល័តនៅតាមឃុំ សង្កាត់។ | ✓ | | | |
| | | 73035 | ការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ជាតិ | ចំណូលទទួលបានពីការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ជាតិ។ | ✓ | | | |
| | | 73036 | ការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ក្រោមជាតិ | ចំណូលទទួលបានពីការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ក្រោមជាតិ។ | | ✓ | ✓ | ✓ |
| | | 73038 | ផលពីការជួលទ្រព្យសម្បត្តិផ្សេងៗ | ផលពីការជួលទ្រព្យសម្បត្តិផ្សេងៗ ក្រៅពីអនុគណនីខាងលើ។ | ✓ | | | |
| | 7304 | | ការផ្ដល់សេវាកម្ម | ចំណូលទទួលបានពីការផ្ដល់សេវាដោយរដ្ឋ។ | ✓ | ✓ | ✓ | ✓ |
| | | 73041 | ផលនៃការដឹកជញ្ជូនទំនិញ | ចំណូលទទួលបានពីការផ្ដល់សេវាដឹកជញ្ជូនទំនិញដោយរដ្ឋ។ | ✓ | | | |
| | | 73042 | កម្រៃនៃការថែទាំ | ចំណូលទទួលបានពីការផ្ដល់សេវាថែទាំ ដូចជាចំណូល ១% បានពីការពិនិត្យ និងព្យាបាលអ្នកជំងឺ ដោយមន្ទីរពេទ្យរដ្ឋ។ ចំណូលទទួលបានពីកម្រៃថែទាំលូ ១០% លើថ្លៃប្រើប្រាស់ទឹកស្អាត កម្រៃថែទាំបរិស្ថាន។ | ✓ | | | |
| | | 73043 | សេវាសុរិយោដី | ចំណូលទទួលបានពីការចុះបញ្ជីក្បាលដី និងការចេញប្លង់កាន់កាប់ដីធ្លី ផ្ទះសម្បែង។ | ✓ | ✓ | ✓ | ✓ |
| | | 73044 | សេវាសំណង់ | ចំណូលទទួលបានពីការអនុញ្ញាតឲ្យសាងសង់។ | ✓ | ✓ | ✓ | ✓ |
| | | 73045 | សេវាលិខិតថ្កោលទោស | ចំណូលបានពីផលនៃសេវាលិខិតថ្កោលទោស ច្រកចេញចូលតែមួយ។ | ✓ | | | |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | ចំណូលទទួលបានពីផលនៃសេវាផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |
| | 7305 | | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងទៀត | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិអចល័ត កម្រៃសេវា និងចំណូលផ្សេងៗ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលកំណត់ដោយច្បាប់។ | | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៩៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | **បរិយាយ** | **សេចក្តីពន្យល់ពីមាតិកាថវិកា** | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | ចំណូលទទួលបានពីកន្លែងធ្វើអាជីវកម្មពិឃាដសត្វនៅតាមសត្តឃាតដ្ឋាន។ | | ✓ | ✓ | |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | ចំណូលទទួលបានពីការជួលតូប រាន ស្តង់លក់ដូរក្នុងទីផ្សារ។ | | ✓ | ✓ | |
| | | 73053 | ចំណូលពីកំពង់ចម្លង | ចំណូលទទួលបានពីការបម្រើសេវាកម្មចម្លងអ្នកធ្វើដំណើរនៅតាមកំពង់ដ ដទទឹង ដបណ្តោយដែលរដ្ឋបានកំណត់។ | | ✓ | ✓ | |
| | | 73054 | ចំណូលពីយៀគ្រី និងកន្លែងបែងចែកផលិតផល | ចំណូលទទួលបានពីអាជីវកម្មដែលធ្វើការប្រមូលផ្តុំ និងបែងចែកការប្រើប្រាស់ផលនេសាទ ដែលរដ្ឋបានកំណត់។ | | ✓ | ✓ | |
| | | 73055 | ចំណូលពីភាស៊ីផ្សារ | ចំណូលដែលបានប្រមូលពីអាជីវករលក់ដូរក្នុងនិងក្រៅទីផ្សារដែលរដ្ឋបានកំណត់។ | | ✓ | ✓ | |
| | | 73058 | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិអចល័តផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | | ✓ | ✓ | ✓ |
| | 7398 | | ចំណូលពីការដោះដូរផ្សេងទៀត | កត់ត្រាចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិផ្សេងៗ ក្រៅពីគណនីខាងលើ។ | ✓ | | | |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | កត់ត្រាចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្មដែលត្រូវទូទាត់ទៅឲ្យរដ្ឋ ចំពោះបទល្មើសនឹងច្បាប់ឬបទបញ្ជារដ្ឋបាល។ ការពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធ ដែលទាក់ទងនឹងពន្ធពិសេសមួយ ត្រូវបានចុះជាចំណូលក្នុងផ្នែកនេះ ប៉ុន្តែការ ផាកពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធផ្សេងៗទៀត ត្រូវបានកត់ត្រានៅក្នុងចំណូលសារពើពន្ធផ្សេងៗទៀត។ | ✓ | ✓ | ✓ | |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | ចំណូលទទួលបានពីការពិន័យចំពោះការមិនអនុវត្តតាមកិច្ចសន្យានៃការជួលអាគារ ឬដីធ្លី... និងចំណូលពីការត្រួតពិនិត្យ ដោយធ្នក់រថយន្តលើសទម្ងន់។ | ✓ | ✓ | ✓ | |
| | 7402 | | ផលពីការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធគយ | ចំណូលទទួលបានពីការពិន័យនិងការដាក់ទណ្ឌកម្មចំពោះបទល្មើសគេចពន្ធដែលរួម សហការរវាងសមត្ថកិច្ចគយ និងអាជ្ញាធរមូលដ្ឋាន។ | ✓ | ✓ | ✓ | |
| 75 | | | **ការឧបត្ថម្ភ អំណោយ** | ការឧបត្ថម្ភឬអំណោយ អាចជាហិរញ្ញវត្ថុឬសម្ភារៈ។ ពាក្យឧបត្ថម្ភត្រូវបានប្រើប្រាស់សំរាប់ការបង្វែរធ្វើដោយរដ្ឋឬអង្គការអន្តរជាតិ រីឯអំណោយមានធម្មជាតិដូចគ្នានឹងការឧបត្ថម្ភ ប៉ុន្តែបានមកពីបុគ្គលឯកជន (បុគ្គល ឬ សមាគម)។ | ✓ | ✓ | ✓ | ✓ |
| | 7501 | | ឧបត្ថម្ភកធនពីថ្នាក់ជាតិ | ចំណូលឧបត្ថម្ភពីថវិកាជាតិផ្តល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ | | ✓ | ✓ | ✓ |
| | 7502 | | ឧបត្ថម្ភកធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ចំណូលឧបត្ថម្ភថវិកា រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ | | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ ...... សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ... ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 75021 | ឧបត្ថម្ភកធនពីរាជធានី ខេត្ត | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលរាជធានី ខេត្ត។ | | ✓ | ✓ | ✓ |
| | | 75022 | ឧបត្ថម្ភកធនពីក្រុង ស្រុក ខណ្ឌ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ។ | | ✓ | ✓ | ✓ |
| | | 75023 | ឧបត្ថម្ភកធនពីឃុំ សង្កាត់ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលឃុំ សង្កាត់។ | | ✓ | ✓ | ✓ |
| | 7503 | | ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន | ចំណូលទទួលបានពីការចែករំលែកពីសមាសភាគអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | | ✓ | ✓ | ✓ |
| | 7504 | | ឧបត្ថម្ភកធនចរន្តពីក្រៅប្រទេសទ្វេភាគី | ចំណូលទទួលបានពីឧបត្ថម្ភកធនពីក្រៅប្រទេសទ្វេភាគី។ | ✓ | ✓ | ✓ | ✓ |
| | 7505 | | ឧបត្ថម្ភកធនចរន្តពីក្រៅប្រទេសពហុភាគី | ចំណូលទទួលបានពីឧបត្ថម្ភកធនពីក្រៅប្រទេសពហុភាគី។ | ✓ | ✓ | ✓ | ✓ |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រសួង ស្ថាប័ន មន្ទីរជំនាញ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | | ✓ | ✓ | ✓ |
| | | 75061 | ពីក្រសួង ស្ថាប័ន | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រសួង ស្ថាប័ន។ | | ✓ | ✓ | ✓ |
| | | 75062 | ពីមន្ទីរជំនាញ | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាមន្ទីរជំនាញ។ | | ✓ | ✓ | ✓ |
| | | 75063 | ពីរាជធានី ខេត្ត | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជារាជធានី ខេត្ត។ | | ✓ | ✓ | ✓ |
| | | 75064 | ពីក្រុង ស្រុក ខណ្ឌ | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រុង ស្រុក ខណ្ឌ។ | | ✓ | ✓ | ✓ |
| | | 75068 | ផ្សេងៗ | ចំណូលទទួលបានពីថ្លៃសេវាក្នុងការអនុវត្តមុខងារជាភ្នាក់ងារផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | | ✓ | ✓ | ✓ |
| | 7507 | | ចំណូលបដិភាគពីប្រជាពលរដ្ឋ-សប្បុរសជន ក្នុងនិងក្រៅប្រទេស | ចំណូលទទួលបានពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស។ | | ✓ | ✓ | ✓ |
| | 7508 | | ចំណូលចរន្តពីប្រភពផ្សេងៗ | ចំណូលទទួលបានពីប្រភពផ្សេងៗ។ | ✓ | ✓ | ✓ | ✓ |
| | 7510 | | មូលនិធិបម្រុង | មូលនិធិបានមកពីការបូកយោងអតិរេកថវិកាជាក់ស្តែងរបស់ឆ្នាំមុនៗសម្រាប់ចំណាយវិនិយោគ។ | | | | ✓ |
| | 7511 | | ឧបត្ថម្ភកធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិកាជាតិផ្តល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |
| | 7512 | | ឧបត្ថម្ភកធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 75121 | ឧបត្ថម្ភកធនពីរាជធានី ខេត្ត សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលរាជធានី ខេត្ត សម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |
| | | 75122 | ឧបត្ថម្ភកធនពីក្រុង ស្រុក ខណ្ឌ សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |
| | | 75123 | ឧបត្ថម្ភកធនពីឃុំ សង្កាត់ សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |
| | 7513 | | ចំណូលពីការចូលរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង | ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋានទៅក្នុងតម្លៃគម្រោង។ | | ✓ | ✓ | ✓ |
| | 7514 | | ឧបត្ថម្ភកធនពីក្រៅប្រទេសទ្វេភាគី សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភកធនមូលធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ។ | ✓ | ✓ | ✓ | ✓ |
| | 7515 | | ឧបត្ថម្ភកធនពីក្រៅប្រទេសពហុភាគី សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភកធនមូលធនពីក្រៅប្រទេស-ពហុភាគីសម្រាប់ចំណាយវិនិយោគ។ | ✓ | ✓ | ✓ | ✓ |
| | 7516 | | ឧបត្ថម្ភកធនទព្វសម្ភារៈបរិក្ខារទ្វេភាគី និងពហុភាគី | ការឧបត្ថម្ភជាទព្វសម្ភារៈបរិក្ខារពី ទ្វេភាគី -ពហុភាគីសម្រាប់វិនិយោគដែលមិនមែនជាហិរញ្ញវត្ថុ។ | | ✓ | ✓ | |
| | 7517 | | ចំណូលពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | ចំណូលដែលបានពីប្រជាពលរដ្ឋ សប្បុរសជនក្នុងនិងក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ។ | | ✓ | ✓ | ✓ |
| | 7518 | | ចំណូលពីប្រភពផ្សេងៗ សម្រាប់ចំណាយវិនិយោគ | ចំណូលទទួលបានពីប្រភពផ្សេងៗទៀតសម្រាប់ចំណាយមូលធនក្រៅពីគណនីទាំងខាងលើ។ | | ✓ | ✓ | ✓ |
| | 7519 | | ឧបត្ថម្ភកធនសម្រាប់ការរំលស់បំណុល | ឧបត្ថម្ភកធនដែលបានទទួលជាសាច់ប្រាក់សម្រាប់សងបំណុល ឬ បានទទួលឧបត្ថម្ភកធន ហើយកាត់កងត្រង់ជាមួយបំណុល។ | ✓ | | | |
| 76 | | | **ផលហិរញ្ញវត្ថុ** | កត់ត្រាចំណូលទទួលបានពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដូចជាការប្រាក់ទទួលបាន ចំណេញពីការប្ដូរប្រាក់។ | ✓ | ✓ | ✓ | ✓ |
| | 7601 | | ការប្រាក់នៃការឲ្យខ្ចី | ចំណូលជាការប្រាក់ពីការឲ្យខ្ចីនូវមូលធន។ | ✓ | | | |
| | | 76011 | ការប្រាក់លើកម្ចី | ចំណូលពីការប្រាក់កម្ចី។ | ✓ | | | |
| | | 76012 | ការប្រាក់លើភតិសន្យាហិរញ្ញវត្ថុ | ចំណូលពីការប្រាក់លើភតិសន្យាហិរញ្ញវត្ថុ។ | ✓ | | | |
| | | 76018 | ចំណូលការប្រាក់ផ្សេងទៀត | ចំណូលពីការប្រាក់ផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | | | |
| | 7602 | | អន្តរការីយកម្មនៃទីផ្សារមូលប័ត្រ | ចំណូលទទួលបានពីការបង់ជាភាគរយដោយទីផ្សារមូលប័ត្រ។ | ✓ | | | |

# ឧបសម្ព័ន្ធទី១ មាតិកាចំណូលថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 7603 | | ភតិសន្យា | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនទិញសម្ភារៈលើការទទួលបានលិខិតធានាដើម្បីខ្ចីលុយពីធនាគារ។ | ✓ | | | |
| | 7604 | | អន្តរការីយកម្មនៃទីផ្សារអចលនវត្ថុ | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនអចលនទ្រព្យក្នុងកាទិញ និងលក់អចលនទ្រព្យ។ | ✓ | | | |
| | 7605 | | អន្តរការីយកម្មនៃទីផ្សារធានារ៉ាប់រង | ចំណូលទទួលបានពីការបង់ជាភាគរយនៃការលក់ប័ណ្ណធានារ៉ាប់រង។ | ✓ | | | |
| | 7606 | | ចំណេញពីការប្តូរប្រាក់ | ចំណូលពីលំអៀងនៃការប្តូរប្រាក់។ | ✓ | | | |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | ចំណូលពីការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងៗទៀត ដែលមិនស្ថិតនៅក្នុងគណនីខាងលើ ដូចជាចំណូលពី ការបង្វែរបៀវត្សនិងប្រាក់បំណាច់ផ្សេងៗ សំណេះចំណាយឆ្លងឆ្នាំ។ | ✓ | ✓ | ✓ | ✓ |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | ត្រូវបានកត់ត្រានៅក្នុងជំពូកនេះនូវចំណែកមួយនៃចំណូលតាមដីកា ដែលជាគំនិតផ្តួចផ្តើមរបស់ធនាគារជាតិ ឬ អាណាប័ក និងកត់ត្រាផងដែរនូវចំណូលពិតដែលបានពីការបោះផ្សាយប្រតិបត្តិការនៃការគ្រប់គ្រង (កម្រៃជើងសារធនាគារ) ឬ ការប្រគល់ឲ្យនូវសកម្មអចលកម្មហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុ។ | ✓ | ✓ | ✓ | ✓ |
| | 7701 | | ផលផ្សេងៗ និងកិច្ចប្រតិបត្តិការគ្រប់គ្រង | ចំណូលទទួលបានពីសេវាធនាគារ និងអតិរេកថវិការាជធានី-ខេត្ត ក្រុង-ស្រុក។ | ✓ | | | |
| | | 77011 | ចំណូលពីការបង់អតិរេករបស់ថវិការាជធានី-ខេត្ត | ចំណូលទទួលបានពីអតិរេកថវិការាជធានី-ខេត្ត ក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ។ | ✓ | | | |
| | | 77012 | ចំណូលពីការបង់អតិរេករបស់ថវិកាក្រុង-ស្រុក | ចំណូលទទួលបានពីអតិរេកថវិកាក្រុង-ស្រុក ក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ។ | ✓ | | | |
| | | 77013 | កម្រៃធនាគារ | ចំណូលទទួលបានពីការប្រើប្រាស់សេវាធនាគារក្នុងប្រតិបត្តិការបង្វែរសាច់ប្រាក់ ដូចជាការបង្វែរលើគណនីបញ្ញើ...។ល។ | ✓ | | | |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | ចំណូលទទួលបានពីការលក់សហគ្រាសសាធារណៈទៅឲ្យឯកជនកាន់កាប់។ | ✓ | | | |
| | 7703 | | ចំណូលពីការលក់ដី រ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | ចំណូលនេះបានមកពីការលក់ដីដែលមានរ៉ែ និងសម្បត្តិធម្មជាតិរបស់រដ្ឋទៅឲ្យឯកជនធ្វើអាជីវកម្ម។ | ✓ | | | |
| | 7704 | | ចំណូលពីការលក់អាគារ | ចំណូលនេះបានមកពីការលក់អាគារ។ | ✓ | ✓ | ✓ | ✓ |
| | 7705 | | ចំណូលពីការលក់ឋបនកម្ម បច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ | ចំណូលនេះបានមកពីការលក់ឋនបកម្មបច្ចេកទេស សម្ភារៈឧបករណ៍ និងហត្ថូបករណ៍ឧស្សាហកម្ម... (គ្រឿងម៉ាស៊ីនដែលប្រើប្រាស់ក្នុងឧស្សហកម្ម)។ | ✓ | ✓ | ✓ | ✓ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 7706 | | ចំណូលពីការលក់រថយន្តដឹកជញ្ជូន | ចំណូលនេះបានមកពីការលក់រថយន្តដឹកជញ្ជូន។ | ✓ | ✓ | ✓ | ✓ |
| | 7707 | | ចំណូលពីការលក់ឧបករណ៍ធុនធ្ងន់ | ចំណូលនេះបានមកពីការលក់នូវឧបករណ៍ធុនធ្ងន់។ | ✓ | ✓ | ✓ | ✓ |
| | 7708 | | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | ចំណូលនេះបានមកពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម (អង្គុលីលេខ កុំព្យូទ័រ ម៉ាស៊ីនថតចម្លង ទូដាក់ឯកសារ និងគ្រឿងសង្ហារឹម ។ល។ | ✓ | ✓ | ✓ | ✓ |
| | 7709 | | ចំណូលពីការលក់សម្ភារៈព័ត៌មានវិទ្យានិងទូរគមនាគមន៍ | ចំណូលនេះបានមកពីការលក់សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍។ | ✓ | | | |
| | 7798 | | ផលផ្សេងៗទៀត | ចំណូលនេះបានមកពីចំណូលផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |
| | | | **ក្រុមទី ២ : ចំណូលតាមដីកា (ប្រភេទទី៣)** | ចំណូលមិនឆ្លងកាត់សាច់ប្រាក់។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី ៣ : ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)** | ចំណូលមិនឆ្លងកាត់សាច់ប្រាក់។ | ✓ | ✓ | ✓ | ✓ |
| 78 | | | **ការបញ្ចូលវិញនូវសំវិធានធន និងរំលស់អចលកម្ម** | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវការរំលស់ ឬការសឹករិចរិលនៃអចលកម្មរូបីនាដំណាច់ការិយបរិច្ឆេទនីមួយៗ។ | ✓ | | | |
| | 7801 | | ការបញ្ចូលវិញនូវរំលស់អចលកម្មអរូបី | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវការរំលស់ ឬការសឹករិចរិលនៃអចលកម្មរូបីនាដំណាច់ការិយបរិច្ឆេទនីមួយៗដូចជា មូលនិធិពាណិជ្ជកម្ម សិទ្ធិក្នុងកតិសន្យា សោហ៊ុយបង្កើតសហគ្រាស សោហ៊ុយស្រាវជ្រាវ និងអភិវឌ្ឍន៍ ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ...។ល។ | ✓ | | | |
| | 7802 | | ការបញ្ចូលវិញនូវរំលស់អចលកម្មរូបី | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវការរំលស់ ឬការសឹករិចរិលនៃអចលកម្មរូបីនាដំណាច់ការិយបរិច្ឆេទនីមួយៗដូចជាដីធ្លី សំណង់ បរិក្ខាបច្ចេកទេស សំភារៈឧបករណ៍ និងហត្ថូបករណ៍ឧស្សាហកម្ម សំភារៈឧបករណ៍ការិយាល័យ សង្ហារឹម សំបកវេចខ្ចប់ប្រមូលវិញ...។ល។ | ✓ | | | |
| | 7803 | | ការបញ្ចូលវិញនូវសំវិធានធនសំរាប់ហានិភ័យ និងបន្ទុក | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវសំវិធានធនសំរាប់ហានិភ័យ និងបន្ទុកដែលបានគ្រោងទុកមួយចំណែកសំរាប់ការចំណាយទៅលើករណីដែលអាចកើតឡើងដោយថាហេតុនៃសហគ្រាសសាធារណៈរបស់រដ្ឋ...។ល។ | ✓ | | | |
| | 7804 | | ការបញ្ចូលវិញនូវការធ្លាក់ចុះតម្លៃអចលកម្មអរូបី | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវចំណាយដែលបានគ្រោងទុកសំរាប់ការខាតបង់ ឬការប្រែប្រួលនៃតម្លៃអចលកម្មអរូបី។ | ✓ | | | |
| | 7805 | | ការបញ្ចូលវិញនូវការធ្លាក់ចុះតម្លៃអចលកម្មរូបី | ចំណូលនេះបានមកពីការបញ្ចូលមកវិញនូវចំណាយដែលបានគ្រោងទុកសំរាប់ការខាតបង់ ឬការប្រែប្រួលនៃតម្លៃអចលកម្មរូបី។ | ✓ | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | | **ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២)** | ចំណូលជាមូលធនប្រមូលផ្តុំគណនីទាំងឡាយដែលទាក់ទងនឹងមូលនិធិផ្ទាល់ ការខ្ចី និងបំណុលប្រហាក់ប្រហែល។ ចំណូលនេះរួមមាន: ចំណូលពិត និងចំណូលតាមដីកា។ | ✓ | ✓ | ✓ | ✓ |
| | | | **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | ចំណូលជាសាច់ប្រាក់ជាក់ស្តែង។ ចំណូលពិតរួមមាន: ចំណូលពីប្រភពផ្ទាល់ និងចំណូលពីប្រភពខាងក្រៅ។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់** | ចំណូលទទួលបានពីក្នុងប្រទេស ។ ចំណូលនេះមានអចលកម្មហិរញ្ញវត្ថុ។ | ✓ | ✓ | ✓ | ✓ |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | ចំណូលប្រភេទនេះរួមមានតម្លៃដែលទទួលបានក្នុងក្របខ័ណ្ឌនៃការចល័តថវិកាដូចជា តម្លៃដែលបានទទួលដោយការឲ្យខ្ចី (កាតហ៊ុន ឬ មូលប័ត្រ)។ | ✓ | | | |
| | 2701 | | ការឲ្យខ្ចី (ការសងវិញនូវមូលធន) | ចំណូលពីការសងមកវិញនូវការឲ្យខ្ចី (ការសងវិញនូវមូលធន)។ | ✓ | | | |
| | 6298 | | អត្ថប្រយោជន៍សង្គមផ្សេងទៀត | ចំណាយលើការឧបត្ថម្ភផ្សេងទៀត ក្រៅពីគណនីខាងលើ ដែលមានឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្រាប់អត្ថប្រយោជន៍សង្គមផ្សេងៗទៀតដូចជា ឧបត្ថម្ភការប្រជុំគណៈបញ្ជាការឯកភាព ឧបត្ថម្ភការប្រឆាំងគ្រឿងញៀន និងឧបត្ថម្ភសម្រាប់ភូមិ ឃុំមានសុវត្ថិភាព...។ល។ | ✓ | ✓ | ✓ | ✓ |
| 65 | | | **ឧបត្ថម្ភធន** | ចំណាយថវិការដ្ឋសម្រាប់ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី អង្គការសាធារណៈ គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល សហគ្រាសសាធារណៈនិងអង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌ បដិភាគរបស់រដ្ឋាភិបាលក្នុងការ អនុវត្តន៍គំរោង វិភាគទានរបស់រដ្ឋាភិបាលដល់អង្គការអន្តរជាតិនានា ជំនួយនិងប្រាក់វិភាជន៍សង្គម។ | ✓ | ✓ | ✓ | ✓ |
| | 6501 | | ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ | ចំណាយថវិការដ្ឋសម្រាប់ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងជាចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពេលដែលពួកគេផ្តល់ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។ | ✓ | ✓ | ✓ | ✓ |
| | | 65011 | ឧបត្ថម្ភធនដល់រាជធានី ខេត្ត | ចំណាយថវិកាសម្រាប់ឧបត្ថម្ភធនដល់រាជធានី ខេត្ត។ | ✓ | ✓ | ✓ | ✓ |
| | | 65012 | ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ | ចំណាយថវិកាសម្រាប់ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ។ | ✓ | ✓ | ✓ | ✓ |
| | | 65013 | ឧបត្ថម្ភធនដល់ឃុំ សង្កាត់ | ចំណាយថវិកាសម្រាប់ឧបត្ថម្ភធនដល់ឃុំ សង្កាត់។ | ✓ | ✓ | ✓ | ✓ |
| | | 65018 | ផ្សេងៗ | ឧបត្ថម្ភធនផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២២ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | **6502** | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ | ការឧបត្ថម្ភកធនដល់អត្តតាហកៈទាំងឡាយ ដែលជាអាជ្ញាធរ អង្គភាពស្ថិតក្រោមអាណាព្យាបាលរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នផ្សេងៗទៀត។ | ✓ | | | |
| | | 65021 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច ដូចជា:<br>-ក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្មនិងជនបទ<br>-អាជ្ញាធរប្រេងកាតជាតិកម្ពុជា<br>-គណៈកម្មការអភិរក្សនិងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ<br>- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា<br>-គណៈកម្មាធិការជាតិដើម្បីប្រជាជននិងអភិវឌ្ឍ<br>-គណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយផលិតផលមួយ<br>-អាជ្ញាធរជាតិទេសចរណ៍កម្ពុជាជាដើម...។ល។ | ✓ | | | |
| | | 65022 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសង្គម | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសង្គម ដូចជា:<br>-គណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា<br>-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី<br>-គណៈកម្មាធិការជាតិអេស្កាប់<br>-អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍<br>-គណៈកម្មការស្រាវជ្រាវរុករកអដ្ឋិធាតុជនជាតិអាមេរិក និងកងទ័ពវៀតណាមដែលបាត់ខ្លួននៅកម្ពុជា ... ជាដើម ។ល។ | ✓ | | | |
| | | 65023 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា មានដូចជា:<br>-ក្រុមប្រឹក្សាភាសាខ្មែរ<br>-គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា<br>-សមាគមជាតិកាយវប្បទិកម្ពុជា<br>-ក្រុមប្រឹក្សាកីឡាកម្ពុជា<br>-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន...ជាដើម។ល។ | ✓ | | | |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៩... សហវ.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 65024 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម មានដូចជា:<br>-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន<br>-គណៈកម្មាធិការជាតិសន្តិសុខលំហសមុទ្រ<br>-អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន<br>-មជ្ឈមណ្ឌលសកម្មភាពកំចាត់មីន<br>-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>-គណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ<br>-គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម<br>-អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស ... ជាដើម។ល។ | ✓ | | | |
| | | 65025 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈវប្បធម៌ | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈវប្បធម៌ មានដូចជា:<br>-ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌<br>-គណៈកម្មការជាតិយូណេស្កូកម្ពុជា<br>-គណៈកម្មាធិការជាតិបេតិកភ័ណ្ឌពិភពលោក<br>-អាជ្ញាធរជាតិព្រះវិហារ ... ជាដើម។ល។ | ✓ | | | |
| | | 65026 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល មានដូចជា: គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ - ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល - ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ - អគ្គនាយកដ្ឋានរាជកិច្ចនិងសេវាកុំព្យូទ័រ - គណៈវិស្វករកម្ពុជា - គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា - អាជ្ញាធរអាងទន្លេសាប ... ជាដើម ។ល។ | ✓ | | | |
| | | 65027 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈច្បាប់ | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈច្បាប់ មានដូចជា: ក្រុមប្រឹក្សាអ្នកច្បាប់ - ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ - គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ - រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ - គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា - អាជ្ញាធរសវនកម្មជាតិនៃកម្ពុជា ... ជាដើម។ល។ | ✓ | | | |
| | | 65028 | ផ្សេងៗ | ឧបត្ថម្ភកធនដល់អង្គភាពផ្សេងៗទៀតក្រៅពីអនុគណនីខាងលើ។ | ✓ | | | |

## ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ...៩៨៩... សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 6503 | | ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | ការឧបត្ថម្ភកធនដល់អត្ថគាហកៈទាំងឡាយ ដែលជាអង្គភាពសាធារណៈមានលក្ខណៈរដ្ឋបាលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួង មានដូចជា:<br>-បេឡាជាតិអតីតយុទ្ធជន<br>-បេឡាជាតិរបបសន្តិសុខសង្គម<br>-មូលនិធិជនពិការ<br>-អាជ្ញាធរអប្សរា ... ជាដើម។ល។ | ✓ | | | |
| | 6504 | | ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ | ការឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈរបស់រដ្ឋដែលមានចំណែកមូលធនភាគច្រើន ។ | ✓ | | | |
| | | 65041 | ឧបត្ថម្ភកធនដល់ក្រុមហ៊ុនរដ្ឋ | ឧបត្ថម្ភកធនដល់ក្រុមហ៊ុនរដ្ឋ មានដូចជា:<br>-កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>-កំពង់ផែស្វយ័តភ្នំពេញ<br>-ភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)<br>-អាជ្ញាធរអគ្គិសនីកម្ពុជា<br>-ក្រុមហ៊ុនហ្គ្រីនត្រេដ<br>-ទូរគមនាគមន៍កម្ពុជា<br>-ធនាគារអភិវឌ្ឍន៍ជនបទ...ជាដើម។ល។ | ✓ | | | |
| | | 65042 | ឧបត្ថម្ភកធនដល់ក្រុមហ៊ុនចម្រុះ | ឧបត្ថម្ភកធនដល់ក្រុមហ៊ុនចម្រុះ មានដូចជា:<br>-ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជារ៉ី)<br>-ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត<br>-ក្រុមហ៊ុនផ្សារមូលប័ត្រកម្ពុជា<br>-ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជាអង្គរអ៊ែរ ... ជាដើម។ល។ | ✓ | | | |

| ជំពូក | គណនី | អនុគណនី | **បរិយាយ** | **សេចក្តីពន្យល់ពីមាតិកាថវិកា** | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 65043 | ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច | ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច មានដូចជា:<br>-ចំការកៅស៊ូស្នួល<br>-ចំការកៅស៊ូបឹងកេត<br>-រដ្ឋាករទឹកស្វយ័តភ្នំពេញ<br>-មន្ទីរពិសោធន៍សំណង់ សាធារណការ<br>-រដ្ឋាករទឹកស្វយ័តសៀមរាប<br>-អគ្គិសនីកម្ពុជា ... ជាដើម។ល។ | ✓ | | | |
| | **6505** | | ឧបត្ថម្ភកធនដល់សហគ្រាសឯកជន | ការឧបត្ថម្ភកធនដល់សហគ្រាសឯកជនក្នុងប្រទេសដែលនៅក្មេងខ្ចីក្នុងការផលិតទំនិញនិងសេវាកម្ម ដើម្បីឲ្យសហគ្រាស នោះអាចប្រកួតប្រជែងលើទីផ្សារបាន។ | ✓ | | | |
| | **6506** | | វិភាគទានដល់អង្គការអន្តរជាតិនានា | ការបង់វិភាគទានរបស់រដ្ឋក្នុងការចូលជាសមាជិកអង្គការអន្តរជាតិ និងប្រាក់វិភាគទានសង្គមដល់អង្គការអន្តរជាតិនានា។ | ✓ | ✓ | ✓ | |
| | | 65061 | អង្គការសហប្រជាជាតិ | ការបង់វិភាគទានរបស់រដ្ឋក្នុងការចូលជាសមាជិកអង្គការសហប្រជាជាតិ និងប្រាក់វិភាគទានសង្គមដល់អង្គការនេះ។ | ✓ | | | |
| | | 65062 | ធនាគារពិភពលោក | ប្រាក់វិភាគទានសង្គមរបស់រដ្ឋ ដល់ធនាគារពិភពលោក។ | ✓ | | | |
| | | 65063 | ធនាគារអភិវឌ្ឍន៍អាស៊ី | ប្រាក់វិភាគទានសង្គមរបស់រដ្ឋ ដល់ធនាគារអភិវឌ្ឍន៍អាស៊ី។ | ✓ | | | |
| | | 65064 | សហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ | ការបង់វិភាគទានរបស់រដ្ឋក្នុងការចូលជាសមាជិកសហព័ន្ធអន្តរជាតិខាងកីឡាផ្សេងៗ និងប្រាក់វិភាគទានសង្គមដល់សហព័ន្ធនេះ។ | ✓ | | | |
| | | 65065 | អង្គការអាស៊ាន | ការបង់វិភាគទានរបស់រដ្ឋក្នុងការចូលជាសមាជិកអង្គការអាស៊ាន និងប្រាក់វិភាគទានសង្គមដល់អង្គការនេះ។ | ✓ | | | |
| | | 65068 | អង្គការអន្តរជាតិផ្សេងៗទៀត | ការបង់វិភាគទានរបស់រដ្ឋក្នុងការចូលជាសមាជិកអង្គការអន្តរជាតិផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | |
| | 6507 | | ការចូលរួមក្នុងការអនុវត្តគំរោង | ចំណាយចរន្តថវិកាបដិភាគរបស់រដ្ឋក្នុងការចូលរួមអនុវត្តគំរោងវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលទាក់ទងទៅនឹងកិច្ចដំណើរការ ដូចជា: ការបណ្តុះបណ្តាល បេសកម្ម.... | ✓ | ✓ | ✓ | ✓ |
| | 6598 | | ឧបត្ថម្ភកធនផ្សេងៗ | ចំណាយលើឧបត្ថម្ភកធនផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី៤ : ចំណាយផ្សេងៗ** | ចំណាយលើពន្ធនិងអាករ និងការសងនិងការបង្វិលវិញ។ | ✓ | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ...១៥៥... សហវ.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| 63 | | | **ពន្ធ និងអាករ** | ពន្ធនិងអាករដែលបង់ដោយរដ្ឋក្នុងក្របខ័ណ្ឌនៃដំណើរការសេវារបស់ខ្លួន។ | ✓ | ✓ | ✓ | |
| | 6301 | | លតាប័ត្រ | ចំណាយលើការបង់ពន្ធយានយន្តប្រចាំឆ្នាំដែលជាកម្មសិទ្ធិរបស់ក្រសួង-ស្ថាប័នរដ្ឋាភិបាល នៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ✓ | ✓ | ✓ | |
| | 6302 | | បន្ទុកពន្ធគយលើការនាំចូលទំនិញនិងសម្ភារៈ | ចំណាយរបស់ក្រសួង-ស្ថាប័នរដ្ឋក្នុងការបង់ពន្ធគយលើការនាំចូលទំនិញ និងសម្ភារៈដែលផ្តល់ដោយបណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍។ | ✓ | | | |
| | 6303 | | បន្ទុកពន្ធប្រថាប់ត្រា | ចំណាយរបស់ក្រសួង ស្ថាប័នរដ្ឋទាំងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការបង់ពន្ធដើម្បីទទួលបាននូវកម្មសិទ្ធិស្របច្បាប់ ដូចជាចំណាយលើការធ្វើប្លង់កម្មសិទ្ធិដីធ្លី។ | ✓ | ✓ | ✓ | |
| | 6304 | | បន្ទុកពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង | ចំណាយរបស់ក្រសួង ស្ថាប័នរដ្ឋ ទាំងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការបង់ពន្ធលើផលទុនដែលទទួលបានពីការជួលដីធ្លី ផ្ទះសម្បែង។ | ✓ | ✓ | ✓ | |
| | 6305 | | បន្ទុកពន្ធគយលើការនាំចូលទំនិញនិងសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) | បន្ទុកពន្ធគយលើការនាំចូលទំនិញនិងសម្ភារៈកសិកម្ម ជាបន្ទុករបស់រដ្ឋ (ការកត់ត្រាជាចំណាយក្នុងអនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណូលជាបន្ទុករបស់រដ្ឋ) | ✓ | | | |
| | 6306 | | បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) | បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ជាបន្ទុករបស់រដ្ឋ (ការកត់ត្រាជាចំណាយក្នុងអនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណូលជាបន្ទុករបស់រដ្ឋ) | ✓ | | | |
| | 6398 | | ពន្ធនិងអាករផ្សេងៗ | ចំណាយរបស់ក្រសួង ស្ថាប័នរដ្ឋ ទាំងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការបង់ពន្ធនិងអាករផ្សេងៗ ក្រៅពីគណនីខាងលើ។ | ✓ | ✓ | ✓ | |
| | 7009 | | ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | ការបង្វិលសងវិញនូវអាករលើតំលៃបន្ថែម ( VAT ) | ✓ | | | |
| | | | **ក្រុមទី២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក (ប្រភេទទី៥ + ប្រភេទទី៦)** | ចំណាយមិនឆ្លងកាត់សាច់ប្រាក់ និងជាប្រតិបត្តិការនៃការបង្វែរ ឬ ផ្ទេរថវិកា។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី៥ : ចំណាយតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)** | ចំណាយមិនឆ្លងកាត់សាច់ប្រាក់ និងជាប្រតិបត្តិការនៃការបង្វែរ ឬ ផ្ទេរថវិកា។ | ✓ | ✓ | ✓ | ✓ |
| 67 | | | **បន្ទុកពិសេស** | ជំពូកនេះកត់ត្រាប្រតិបត្តិការនៃថវិកាតាមដីកាដែលធ្វើជាកម្មវត្ថុនៃការបោះផ្សាយអាណត្តិ ប៉ុន្តែការបោះផ្សាយនេះមិនឆ្លង កាត់ចលនាសាច់ប្រាក់របស់រតនាគារទេ។ ប្រតិបត្តិការនេះគឺជាគំនិតផ្តួចផ្តើមរបស់រតនាគារ ឬ អាណាប័ក។ | ✓ | ✓ | ✓ | ✓ |

| ជំពូក | គណនី | អនុគណនី | **បរិយាយ** | **សេចក្តីពន្យល់ពីមាតិកាថវិកា** | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 6701 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន | គណនីនេះកត់ត្រាសម្រាប់ការចំណាយមួយនៃថវិកាតាមដីកា ដើម្បីធ្វើឲ្យត្រឹមត្រូវតាមច្បាប់នូវ ឱនភាព ឬ ឥណទេយ្យគណនេយ្យឆ្នាំមុនដែលត្រូវបានលុបចោល។ | ✓ | ✓ | ✓ | |
| | | 67011 | ការកាត់កង បំណុលតឹងទារ ដែលទារមិនបាន | ជាបំណុលដែលមិនអាចប្រមូលបាន ដូច្នេះហើយវាមិនមានតំលៃទៀតទេចំពោះម្ចាស់បំណុល។ រាជរដ្ឋាភិបាលជាធម្មតាមានទឹកប្រាក់ចំណូលដែលនឹងត្រូវទទួល ប៉ុន្តែទឹកប្រាក់នោះ ត្រូវបានលុបចោលនៅពេលដែលរដ្ឋាភិបាលមានភស្តុតាងថាកូនបំណុលមិនមានលទ្ធភាពសងបំណុលរបស់គេ។ ឧទាហរណ៍ ប្រាក់ពន្ធត្រូវទទួល...។ល។ | ✓ | ✓ | ✓ | |
| | | 67012 | ផលចំណេញពីការលក់អចលកម្ម ដែលទារមិនបាន | ចំណាយនេះសំដៅដល់ចំណេញពីការលក់ចោលទ្រព្យសកម្មរយៈពេលវែងដែលអ្នកទិញ បដិសេធមិនព្រមបង់ប្រាក់ ឬ មិនអាចមានលទ្ធភាពបង់ប្រាក់ ឬ បាត់ខ្លួន។ ចំណេញលើការលក់ចោលទ្រព្យសកម្មរយៈពេលវែងកើតមានឡើងនៅពេលដែលចំណូលពីការលក់លើស តំលៃយោងនៃទ្រព្យសកម្មនោះ។ | ✓ | ✓ | ✓ | |
| | 6705 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) | គណនីនេះកត់ត្រាតំលៃពិតគណនេយ្យនៃទ្រព្យអចលកម្ម ដែលបានលក់ក្រោយពីអស់អាយុកាលប្រើប្រាស់ ដែលបានកំណត់នៅក្នុងការកាត់រំលស់។ | ✓ | ✓ | ✓ | ✓ |
| 68 | | | **ទាយជ្ជទានឲ្យដល់រំលស់អចលកម្ម** | ជំពូកនេះកត់ត្រាប្រតិបត្តិការថវិកាតាមដីកា (មិនពាក់ព័ន្ធសាច់ប្រាក់) គឺជាការចំណាយសម្រាប់រំលស់អចលកម្មដែលបានប្រើប្រាស់។ | ✓ | ✓ | ✓ | ✓ |
| | 6801 | | ទាយជ្ជទានឲ្យដល់រំលស់អចលកម្មអរូបី | ចំណាយសម្រាប់ការរំលស់អចលកម្មអរូបី។ | ✓ | ✓ | ✓ | ✓ |
| | 6802 | | ទាយជ្ជទានឲ្យដល់រំលស់អចលកម្មរូបី | ចំណាយសម្រាប់ការរំលស់អចលកម្មរូបី។ | ✓ | ✓ | ✓ | ✓ |
| | 6803 | | ទាយជ្ជទានឲ្យដល់រំលស់ទ្រព្យសម្បត្តិវិនិយោគ | ជាចំណាយពីការប្រើប្រាស់ទ្រព្យវិនិយោគ ប្រសិនបើរដ្ឋាភិបាលបានជ្រើសរើសវិធីសាស្ត្រ ថ្លៃដើមដើម្បីវាស់វែងទ្រព្យវិនិយោគបន្ទាប់ពីការទទួលស្គាល់លើកដំបូង។ | ✓ | | | |
| | 6804 | | សំវិធានធនសម្រាប់ហានិភ័យនិងចំណាយ | សំវិធានធនជាបំណុលដែលមានទឹកប្រាក់ និងពេលវេលាមិនច្បាស់លាស់។ រាជរដ្ឋាភិបាល ធ្វើសំវិធានធនចំពោះកាតព្វកិច្ចរបស់ខ្លួនដែលកើតឡើងពីព្រឹត្តិការណ៍ពីអតីតកាល ដូចជា សំវិធានធនសំរាប់ការធានាជាដើម។ | ✓ | | | |
| | 6805 | | ទាយជ្ជទានឲ្យដល់ការធ្លាក់ចុះតម្លៃអចលកម្មអរូបី | ចំណាយសម្រាប់ការធ្លាក់ចុះតម្លៃអចលកម្មអរូបី។ | ✓ | | | |
| | 6806 | | ទាយជ្ជទានឲ្យដល់ការធ្លាក់ចុះតម្លៃអចលកម្មរូបី | ចំណាយសម្រាប់ការធ្លាក់ចុះតម្លៃអចលកម្មរូបី។ | ✓ | | | |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២២ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | | **ប្រភេទទី៦ : ចំណាយមិនបានគ្រោងទុក** | គឺជាឥណទានដែលសភាបានអនុម័តសម្រាប់ចំណាយលើការងារចាំបាច់របស់រាជរដ្ឋាភិបាល។ | ✓ | ✓ | ✓ | ✓ |
| 69 | | | **ចំណាយមិនបានគ្រោងទុក** | ឥណទានច្បាប់អនុម័តនៅក្នុងជំពូកនេះ មិនត្រូវបានប្រើប្រាស់សម្រាប់បោះផ្សាយអាណត្តិបើកប្រាក់ទេ គឺទុកសម្រាប់តែធ្វើនិយ័តភាពតែប៉ុណ្ណោះ។ | ✓ | ✓ | ✓ | ✓ |
| | 6901 | | ចំណាយត្រៀមបំរុង | ឥណទានច្បាប់អនុម័តនៅក្នុងគណនីនេះ គឺទុកសម្រាប់តែធ្វើនិយ័តភាពដើម្បីបម្រើឲ្យសកម្មភាពត្រៀមបំរុងចាំបាច់របស់រដ្ឋាភិបាល ដូចជាគ្រោះធម្មជាតិ ការរៀបចំការបោះឆ្នោត។ | ✓ | | | |
| | 6902 | | ចំណាយផ្សេងៗ | ឥណទានច្បាប់អនុម័តនៅក្នុងគណនីនេះ គឺទុកសម្រាប់តែធ្វើនិយ័តភាពជូនក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបម្រើឲ្យសកម្មភាពចាំបាច់ ដែលពុំអាចដឹងមុនបាន ហើយដែលសកម្មភាពទាំងនោះមិនបានគ្រោងទុកនៅក្នុងកញ្ចប់ថវិការបស់ខ្លួន។ | ✓ | ✓ | ✓ | ✓ |
| | | | **ខ.សរុបចំណាយមូលធន ( ក្រុមទី១ + ក្រុមទី២ )** | ចំណាយលើការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល ដើម្បីធ្វើហិរញ្ញប្បទានដល់ការវិនិយោគ និងរាល់ចំណាយ ដើម្បីទទួលបាននូវបេតិកភណ្ឌ ឬ ទ្រព្យសម្បត្តិរបស់រដ្ឋ ( ការទិញសម្ភារៈប្រើប្រាស់យូរឆ្នាំ សំណង់ ការរៀបចំអគារជា ទ្រង់ទ្រាយធំ ការងារហេដ្ឋារចនាសម្ព័ន្ធ ) ចំណាយនេះរួមមានៈ ចំណាយពិត និងចំណាយតាមដីកា។ | ✓ | ✓ | ✓ | ✓ |
| | | | **ក្រុមទី១ : ចំណាយពិត ( ប្រភេទទី១ + ប្រភេទទី២ )** | ចំណាយជាសាច់ប្រាក់ជាក់ស្ដែង។ ចំណាយនេះរួមមានៈ ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល និងចំណាយលើអចលកម្ម។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី១ : ការទូទាត់ប្រាក់ខ្ចី និងបំណុលប្រហាក់ប្រហែល** | ចំណាយរួមលើការទូទាត់សងកម្ចី និងបំណុលហិរញ្ញវត្ថុប្រហាក់ប្រហែល។ | ✓ | ✓ | ✓ | ✓ |
| 50 | | | **ការខ្ចី** | ជំពូកនេះកត់ត្រារាល់កម្ចី និងបំណុលហិរញ្ញវត្ថុប្រហាក់ប្រហែលនឹងកម្ចី។ | ✓ | | | |
| | 5001 | | ការខ្ចី ក្នុងប្រទេស | ចំណាយសងប្រាក់ដើមនៃកម្ចីក្នុងប្រទេសដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | 50011 | ធនាគារជាតិនៃកម្ពុជា | ចំណាយសងប្រាក់ដើមនៃកម្ចីពីធនាគារជាតិនៃកម្ពុជាដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | 50012 | ធនាគារពាណិជ្ជ | ចំណាយសងប្រាក់ដើមនៃកម្ចីពីធនាគារពាណិជ្ជដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | 50018 | ផ្សេងៗ | ចំណាយសងប្រាក់ដើមនៃកម្ចីក្នុងប្រទេសផ្សេងៗទៀតដែលដល់ពេលកំណត់សង។ | ✓ | | | |
| | 5002 | | ការខ្ចី ក្រៅប្រទេសពីពហុភាគី | ចំណាយសងប្រាក់ដើមនៃកម្ចីពីពហុភាគីដែលដល់ពេលកំណត់សង ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងបណ្ដាអង្គការអន្តរជាតិនានា។ | ✓ | | | |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 5003 | | ការខ្ចី ក្រៅប្រទេសពីទ្វេភាគី | ចំណាយសងប្រាក់ដើមនៃកម្ចីពីទ្វេភាគីដែលដល់ពេលកំណត់សង ដូចជា ជប៉ុន អាល្លឺម៉ង់ បារាំង និងបណ្តាប្រទេសផ្សេងៗទៀត។ | ✓ | | | |
| | 5004 | | ការខ្ចី ពីទីផ្សារហិរញ្ញវត្ថុរយៈពេលវែង | ចំណាយលើការសងប្រាក់ដើមនៃការបោះផ្សាយសញ្ញាប័ណ្ណ និងប័ណ្ណរដ្ឋាភិបាលដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | 50041 | សញ្ញាប័ណ្ណ | ចំណាយលើការសងប្រាក់ដើមនៃការបោះផ្សាយសញ្ញាប័ណ្ណ ដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | 50042 | ប័ណ្ណរដ្ឋាភិបាល | ចំណាយលើការសងប្រាក់ដើមនៃការបោះផ្សាយប័ណ្ណរដ្ឋាភិបាល ដែលដល់ពេលកំណត់សង។ | ✓ | | | |
| | | | **ប្រភេទទី ២ : អចលកម្ម** | ចំណាយលើអចលកម្មអរូបី អចលកម្មរូបី ភាគកម្ម និងឥណទេយ្យពាក់ព័ន្ធទៅនឹងអចលកម្មហិរញ្ញវត្ថុផ្សេងៗ។ | ✓ | ✓ | ✓ | ✓ |
| 20 | | | **អចលកម្មអរូបី** | គឺជាអចលកម្មផ្សេងៗទៀតក្រៅពីរូបីនិងហិរញ្ញវត្ថុ ហើយអចលកម្មនេះរួមមាន សោហ៊ុយសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល។ ជំពូកនេះគឺជាប្រតិបត្តិការតាមដីកា នៅពេលការងារចប់សព្វ គ្រប់ជំពូកនេះត្រូវបានធ្វើនិយ័តកម្មទៅក្នុងជំពូក ២១។ | ✓ | ✓ | ✓ | |
| | 2003 | | សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ | ចំណាយទៅឱ្យសហគ្រាសឬក្រុមហ៊ុនឯកជន ជានីតិបុគ្គលនិងរូបវន្តបុគ្គល លើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យសម្រេចនូវការងារវិនិយោគមួយ។ នៅពេលការងារត្រូវបានបញ្ចប់សព្វគ្រប់គណនី ២០០៣នេះ ត្រូវធ្វើនិយ័តកម្មទៅក្នុងជំពូក២១។ | ✓ | ✓ | ✓ | |
| | | 20031 | សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ | ចំណាយទៅឱ្យសហគ្រាសឬក្រុមហ៊ុនឯកជន ជានីតិបុគ្គលនិងរូបវន្តបុគ្គល លើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យសម្រេចនូវការងារវិនិយោគមួយ។ | ✓ | ✓ | ✓ | |
| | | 20038 | ផ្សេងៗ | ចំណាយផ្សេងៗទៀត ទាក់ទងនឹងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យសម្រេចនូវការងារវិនិយោគមួយ។ | ✓ | ✓ | ✓ | |
| | 2005 | | ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល | ចំណាយទៅលើការស្នើសុំប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែលដើម្បីធ្វើឱ្យសម្រេចនូវការងារវិនិយោគមួយ។ នៅពេលការងារចប់សព្វគ្រប់ គណនីនេះត្រូវបានធ្វើនិយ័តកម្មទៅក្នុងជំពូក ២១។ | ✓ | ✓ | ✓ | |
| | | 20051 | ប្រកាសនីយប័ត្រ | ចំណាយទៅលើការស្នើសុំប្រកាសនីយប័ត្រ ដើម្បីធ្វើឱ្យសម្រេចនូវការងារវិនិយោគមួយ។ | ✓ | ✓ | ✓ | |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 20052 | អាជ្ញាប័ណ្ណ | ចំណាយទៅលើការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើឲ្យសម្រេចនូវការងារវិនិយោគមួយ។ | ✓ | ✓ | ✓ | |
| | | 20053 | សិទ្ធិប្រហាក់ប្រហែល | ចំណាយទៅលើការស្នើសុំសិទ្ធិប្រហាក់ប្រហែល ដើម្បីធ្វើឲ្យសម្រេចនូវការងារវិនិយោគមួយ។ | ✓ | ✓ | ✓ | |
| | | 20054 | កម្មវិធីកុំព្យូទ័រ | ចំណាយទៅលើកម្មវិធីកុំព្យូទ័រ។ | ✓ | ✓ | ✓ | |
| | | 20058 | ផ្សេងៗ | ចំណាយផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | |
| 21 | | | **អចលកម្មរូបី** | ជំពូកនេះកត់ត្រារាល់ការចំណាយលើការទិញនិងកែលម្អដីធ្លី និងធនធានធម្មជាតិ ចំណាយលើការសាងសង់អគារនិង ហេដ្ឋារចនាសម្ព័ន្ធ ចំណាយលើបរិក្ខារ បច្ចេកទេស សម្ភារៈ និងឧបករណ៍ និងចំណាយលើការទិញអចលកម្មផ្សេងៗទៀតដែលត្រូវបានចាត់ថ្នាក់នៅក្នុងចំណាយជាមូលធន។ | ✓ | ✓ | ✓ | ✓ |
| | **2101** | | ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | ចំណាយលើការទិញដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិ ដើម្បីបម្រើឲ្យការងាររដ្ឋាភិបាល។ | ✓ | ✓ | ✓ | |
| | | 21011 | ដីធ្លី | ចំណាយលើការទិញដីធ្លី។ ដីធ្លីរួមមាន ដី និងផ្ទៃទឹក។ ផ្ទៃទឹករួមមានបឹង ព្រែក និងផ្លូវទឹកខាងក្នុង។ ដីធ្លីអាចមាន សណ្ឋាន ជាដីធម្មជាតិ (សម្រាប់ការដាំដុះ) ដីសម្រាប់សាងសង់គ្រប់ប្រភេទ។ | ✓ | ✓ | ✓ | |
| | | 21012 | ដីរ៉ែ | ចំណាយលើការទិញដីរ៉ែ។ ដីរ៉ែគឺជាដីបំរុងដែលត្រូវបានទទួលស្គាល់ថាមានរ៉ែគ្រប់ប្រភេទដូចជា ប្រេង ឧស្ម័នធម្មជាតិ ត្បូងថ្ម រ៉ែដែក (រ៉ែដែក និងរ៉ែមានតំលៃ) និងរ៉ែមិនមែនដែក (កន្លែងយកថ្ម ដីឥដ្ឋ ដីខ្សាច់ ដីបំរុងដែលមានសារធាតុគីមី រ៉ែសម្រាប់ធ្វើជី ដីស្រែអំបិល កន្លែងស្តុកហ្គាស ត្បូង កៅស៊ូក្រាលថ្នល់ ត្បូងថ្មផ្សេងៗ...)។ ប្រសិនជាការចំណាយលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីធ្វើអាជីវកម្មនៃស្រទាប់លោហធាតុក្រោមដី ការចំណាយនោះត្រូវកត់ត្រាក្នុងគណនី ២១០៤។ | ✓ | | | |
| | | 21018 | សម្បត្តិធម្មជាតិផ្សេងៗ | ចំណាយលើការទិញសម្បត្តិធម្មជាតិផ្សេងៗ ដូចជាធនធានជីវសាស្ត្រមិនមានលក្ខណៈដាំដុះ ដូចជាសត្វគ្រប់ប្រភេទ និងដើមឈើ។ | ✓ | ✓ | ✓ | |
| | **2102** | | ការរៀបចំកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | ចំណាយលើការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗដែលរដ្ឋជាកម្មសិទ្ធិករ ហើយការកែលម្អនេះ បានធ្វើឲ្យកើន ឡើងនូវតំលៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិទាំងនោះ។ ការកែលម្អនេះ បានបង្កើននូវវិសាលភាព គុណភាពនិងផលិតភាពនៃដី ឬ រាំងដល់ការបំផ្លាញរបស់វា។ | ✓ | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៩... សហវ.ប្រក ចុះថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | **បរិយាយ** | **សេចក្តីពន្យល់ពីមាតិកាថវិកា** | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 21021 | ការរៀបចំកែលម្អដីធ្លី | ចំណាយលើការរៀបចំកែលម្អដីធ្លីក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានធ្វើឲ្យកើនឡើងនូវតំលៃដីនោះដូចជា ការចាក់ដីបំពេញ។ | ✓ | ✓ | ✓ | ✓ |
| | | 21022 | ការរៀបចំកែលម្អដីរ៉ែ | ចំណាយលើការរៀបចំកែលម្អដីរ៉ែក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានធ្វើឲ្យកើនឡើងនូវវិសាលភាពនៃការធ្វើអាជីវកម្ម។ | ✓ | | | |
| | | 21028 | ការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗ | ចំណាយលើការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានបង្កើននូវវិសាលភាព គុណភាព និងផលិតភាពនៃធនធានធម្មជាតិ ឬ រារាំងដល់ការបំផ្លាញរបស់វា។ | ✓ | ✓ | ✓ | ✓ |
| | **2103** | | **សំណង់អគាររដ្ឋបាល និងការកែលម្អ** | ចំណាយលើការសាងសង់អគារ និង សំណង់ផ្សេងៗទៀត និង ចំណាយលើការកែលម្អអគារ ដែលរដ្ឋជាកម្មសិទ្ធិករ។ | ✓ | ✓ | ✓ | ✓ |
| | | 21031 | សំណង់អគាររដ្ឋបាល | ចំណាយលើការសាងសង់អគាររដ្ឋបាលសម្រាប់បម្រើឲ្យការងាររដ្ឋាភិបាល។ | ✓ | ✓ | ✓ | ✓ |
| | | 21032 | ការកែលម្អអគាររដ្ឋបាល | ចំណាយលើការរៀបចំកែលម្អអគារក្នុងទ្រង់ទ្រាយធំ ហើយការងារនេះបានធ្វើឲ្យកើនឡើងនូវតំលៃអគារនោះ ដូចជា ការជួសជុលធំបូល ការជួសជុលរួមនៃប្រព័ន្ធអគ្គិសនី។ល។ រីឯការជួសជុលតូចតាចដូចជា ការបន្ថែមផ្ទាំងគំនូរការជួស ជុលបង្អួច ការលាបពណ៌ ត្រូវបញ្ចូលក្នុងថ្នាក់ ៦ (ចំណាយចរន្ត)។ | ✓ | ✓ | ✓ | ✓ |
| | | 21038 | សំណង់ផ្សេងៗ | ចំណាយលើការសាងសង់ផ្សេងៗ ដែលមិនមែនជាអគារ ដូចជាវិមានឯករាជ្យ ជញ្ជាំងព្រះបរមរាជវាំង។ | ✓ | ✓ | ✓ | ✓ |
| | **2104** | | ហេដ្ឋារចនាសម្ព័ន្ធ | ចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ | ✓ | ✓ | ✓ | ✓ |
| | | 21041 | ផ្លូវថ្នល់ | ចំណាយលើការសាងសង់ផ្លូវថ្នល់ ដូចជា ផ្លូវឡាន ផ្លូវថ្មើរជើង ស្ពាន ការដាក់ប្រព័ន្ធលូ ដែលពាក់ព័ន្ធទៅនឹងការសាងសង់ផ្លូវថ្នល់។ | ✓ | ✓ | ✓ | ✓ |
| | | 21042 | ធារាសាស្ត្រ | ចំណាយលើការសាងសង់ប្រព័ន្ធធារាសាស្ត្រ ដូចជា ផ្លូវទឹក ទំនប់ ព្រែកជីក ការជីកស្រះ។ | ✓ | ✓ | ✓ | ✓ |
| | | 21043 | អាយស្ម័យយាន | ចំណាយលើការសាងសង់អាយស្ម័យយាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឲ្យអាយស្ម័យយាន ដូចជាផ្លូវដែក ព្រែកជីកសម្រាប់រថភ្លើងឆ្លងកាត់។ | ✓ | | | |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៩៥..... សហវ.ប្រក ចុះថ្ងៃទី២២ ខែ [illegible] ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 21044 | អាកាសយានដ្ឋាន | ចំណាយលើការសាងសង់អាកាសយានដ្ឋាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឲ្យអាកាសយានដ្ឋាន ដូចជា កន្លែងចុះចតយន្តហោះ។ | ✓ | | | |
| | | 21045 | ទូរគមនាគមន៍ | ចំណាយលើការតំលើងប្រព័ន្ធទូរគមនាគមន៍ ដូចជា ខ្សែទូរគមនាគមន៍ អង់តែនសម្រាប់ទទួលផ្កាយរណប ខ្សែកាប។ | ✓ | | | |
| | | 21046 | អគ្គិសនី | ចំណាយលើការសាងសង់វារីអគ្គិសនី និងចំណាយផ្សេងៗទៀតដើម្បីបម្រើឲ្យការងារអគ្គិសនី ដូចជាខ្សែភ្លើងទប់អគ្គិសនី កំលាំងខ្ពស់។ | ✓ | ✓ | ✓ | |
| | | 21047 | បណ្តាញបង្ហូរទឹក និងអនាម័យ | ចំណាយលើការសាងសង់បណ្តាញបង្ហូរទឹកដូចជា ការដាក់ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ការជីកអាងស្តុកទឹកសម្រាប់ការធ្វើបន្សុតទឹកកខ្វក់។ | ✓ | ✓ | ✓ | ✓ |
| | | 21048 | ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | ចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ ដូចជា ពហុកីឡដ្ឋាន មជ្ឈមណ្ឌលកំសាន្ត លូទឹកស្អុយ អណ្តូង និងកន្លែងធ្វើអាជីវកម្មស្រទាប់រ៉ែនៅក្រោមដី។ | ✓ | ✓ | ✓ | ✓ |
| | 2105 | | ឋបនកម្ម បច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ | ចំណាយលើឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ ដែលត្រូវបានចាត់ថ្នាក់នៅក្នុងចំណាយជាមូលធន។ | ✓ | ✓ | ✓ | |
| | | 21051 | ឋបនកម្ម បច្ចេកទេស | ចំណាយលើឋបនកម្មបច្ចេកទេស ដូចជាកន្លែងសម្រាប់បំពង់បូមទឹកពន្លត់អគ្គិភ័យ និងសម្ភារៈរបស់វា និងយានដ្ឋាន។ | ✓ | ✓ | ✓ | |
| | | 21052 | សម្ភារៈ | ចំណាយលើការទិញសម្ភារៈផ្សេងៗ ដូចជាសម្ភារៈសម្រាប់ធ្វើរោងទំនិញ រោងជាង និងយានដ្ឋាន សម្ភារៈអគ្គីភ័យ សម្ភារៈ ផ្លូវថ្នល់ និងសម្ភារៈការងារសាធារណៈ ដែលទំហំទឹកប្រាក់ចំណាយនោះត្រូវបានចាត់ជាចំណាយមូលធន។ | ✓ | ✓ | ✓ | |
| | | 21053 | គ្រឿងឧបករណ៍ (ហត្ថបករណ៍) | ចំណាយលើគ្រឿងឧបករណ៍ធំ ដែលមានឯកតាខ្ពស់ធៀបទៅនឹងដែនកំណត់អចលកម្ម។ | ✓ | ✓ | ✓ | |
| | | 21058 | ផ្សេងៗ | ចំណាយលើឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថបករណ៍ផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | ✓ | ✓ | |
| | 2106 | | ស្នាដៃសិល្បៈនិងការប្រមូល (សន្សំ) | ចំណាយលើស្នាដៃសិល្បៈ និងការប្រមូល ដូចជាផ្ទាំងគំនូរ រូបបដិមា ការប្រមូលកាក់លុយ ការប្រមូលសៀវភៅចាស់ៗ។ | ✓ | | | |
| | 2108 | | អចលកម្មរូបីផ្សេងទៀត | ចំណាយលើអចលកម្មរូបីផ្សេងៗទៀតដូចជា សម្ភារៈឧបករណ៍ដឹកជញ្ជូន សម្ភារៈការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម ដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយ ជាមូលធន ដោយផ្អែកទៅលើទំហំទឹកប្រាក់ និងអាយុកាល។ | ✓ | ✓ | ✓ | ✓ |

ភ្ជាប់ជាមួយប្រកាសលេខ ១៩៨៥ សហវ.ប្រក ចុះថ្ងៃទី២២ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 21081 | សម្ភារៈ ឧបករណ៍ដឹកជញ្ជូន | ចំណាយលើការទិញសម្ភារៈឧបករណ៍ដឹកជញ្ជូន ដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយជាមូលធន។ | ✓ | ✓ | ✓ | |
| | | 21082 | សម្ភារៈ ឧបករណ៍ការិយាល័យ | ចំណាយលើការទិញសម្ភារៈឧបករណ៍ការិយាល័យ ដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយជាមូលធន។ | ✓ | ✓ | ✓ | ✓ |
| | | 21083 | សម្ភារៈ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ចំណាយលើការទិញសម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយជាមូលធន។ | ✓ | ✓ | ✓ | ✓ |
| | | 21084 | សង្ហារឹម | ចំណាយលើការទិញសង្ហារឹម ដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយជាមូលធន។ | ✓ | ✓ | ✓ | ✓ |
| | | 21088 | អចលកម្មរូបីផ្សេងៗ | ចំណាយលើការទិញអចលកម្មរូបីផ្សេងទៀតដែលត្រូវបានចាត់ថ្នាក់នៅក្រោមចំណាយជាមូលធន ហើយដែលមិនមាននៅក្នុងអនុគណនីខាងលើ។ | ✓ | ✓ | ✓ | ✓ |
| 22 | | | **ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង** | ទ្រព្យវិនិយោគគឺជាទ្រព្យ (ដី ឬ អគារ ឬ ផ្នែកនៃអគារ ឬ ទាំងពីរ) ត្រូវបានរក្សាទុកដើម្បី រកចំណូលតាមការជួល ឬ សំរាប់បង្កើនដើមទុន ឬ ក៏ទាំងពីរ។ | ✓ | | | |
| | 2201 | | ទ្រព្យសម្បត្តិវិនិយោគ ដីធ្លី | ដីដែលត្រូវបានរក្សាទុកសំរាប់ការបង្កើនដើមទុនរយៈពេលវែងជាជាងសំរាប់ការលក់ក្នុង រយៈពេលខ្លីនៅក្នុងកិច្ចដំណើរការធម្មតា។ ឧទាហរណ៍ ដីដែលត្រូវបានរក្សាទុកដោយ មន្ទីរពេទ្យសំរាប់ការបង្កើនដើមទុនដែលអាចត្រូវបានលក់នៅពេលមានអត្ថប្រយោជន៍នាពេលអនាគត។ | ✓ | | | |
| | 2202 | | ទ្រព្យសម្បត្តិវិនិយោគ អគារ និងសំណង់ | អគារនិងរចនាសម្ព័ន្ធត្រូវបានរក្សាទុកដើម្បីរកចំណូលតាមការជួល ឬ សំរាប់ការបង្កើនដើមទុន ឬ ទាំងពីរ។ ឧទាហរណ៍ សាកលវិទ្យាល័យមួយអាចមានអគារដែលខ្លួនជួលទៅឲ្យភាគីខាងក្រៅដោយផ្នែកលើមូលដ្ឋានពាណិជ្ជកម្ម។ | ✓ | | | |
| 23 | | | **អចលកម្មកំពុងដំណើរការ** | ចំណាយពាក់ព័ន្ធនឹងអចលកម្មដើម្បីធ្វើឲ្យសម្រេចនូវការងារវិនិយោគមួយ ដែលការងារនោះនឹងត្រូវបញ្ចប់ក្នុងរយៈពេល យូរនិងត្រូវធ្វើការទូទាត់ចំណាយច្រើនលើក ដូចជាការសាងសង់ផ្លូវមួយខ្សែដែលត្រូវបញ្ចប់ក្នុងរយៈពេលបីឆ្នាំ។ ដូច្នេះ នៅក្នុងអំឡុងពេលអនុវត្តការងារវិនិយោគនេះដែលមិនទាន់បានបញ្ចប់ទាំងស្រុងនៅឡើយ រាល់ការចំណាយលើអចល កម្មរូបីនិងអរូបី ត្រូវបានកត់ត្រានៅក្នុងជំពូកនេះ។ ប៉ុន្តែនៅពេលដែលការងារនេះត្រូវបានបញ្ចប់ អាណាប័កជូនព័ត៌មាន ទៅរតនាគារ (បញ្ជាក់ពីការងារបានបញ្ចប់ ឬ ការទូទាត់ចុងក្រោយ) ហើយការចំណាយដែលបានកត់ត្រាក្នុងជំពូក ២៣ នេះ ត្រូវបានធ្វើនិយ័តកម្មទៅគណនីអចលកម្មពាក់ព័ន្ធនៃជំពូក ២០ និង២១ ។ | ✓ | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | 2300 | | អចលកម្មអរូបី (កំពុងដំណើរការ) | ចំណាយលើអចលកម្មអរូបីកំពុងដំណើរការ រួមមាន សោហ៊ុយសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល។ | ✓ | ✓ | ✓ | |
| | | 23003 | សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ (កំពុងដំណើរការ) | ចំណាយទៅឲ្យសហគ្រាសឬក្រុមហ៊ុនឯកជន ជានីតិបុគ្គលនិងរូបវន្តបុគ្គល លើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យសម្រេចនូវការងារវិនិយោគមួយ (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | |
| | | 23005 | ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល (កំពុងដំណើរការ) | ចំណាយទៅលើការស្នើសុំប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែលដើម្បីធ្វើឲ្យសម្រេចនូវការងារវិនិយោគមួយ កំពុងដំណើរការ។ | ✓ | ✓ | ✓ | |
| | 2302 | | ការកែលម្អ ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ) | ចំណាយលើការកែលម្អដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗដែលរដ្ឋជាកម្មសិទ្ធិករ ហើយការកែលម្អនេះ បានធ្វើឲ្យកើន ឡើងនូវតំលៃដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិទាំងនោះ។ ការកែលម្អនេះ បានបង្កើននូវវិសាលភាព គុណភាព និងផលិតភាពនៃដី ឬ រាំងដល់ការបំផ្លាញរបស់វា (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23021 | ការកែលម្អដីធ្លី (កំពុងដំណើរការ) | ចំណាយលើការរៀបចំកែលម្អដីធ្លីក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានធ្វើឲ្យកើនឡើងនូវតំលៃដីនោះដូចជាការ ចាក់ដីបំពេញ (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23022 | ការកែលម្អដីរ៉ែ (កំពុងដំណើរការ) | ចំណាយលើការរៀបចំកែលម្អដីរ៉ែក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានធ្វើឲ្យកើនឡើងនូវវិសាលភាពនៃការធ្វើអាជីវកម្ម (កំពុងដំណើរការ)។ | ✓ | | | |
| | | 23028 | ការកែលម្អសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ) | ចំណាយលើការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗក្នុងទ្រង់ទ្រាយធំ ហើយការងារកែលម្អនេះបានបង្កើននូវវិសាលភាព គុណភាព និងផលិតភាពនៃធនធានធម្មជាតិ ឬរាំងដល់ការបំផ្លាញរបស់វា (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | 2303 | | សំណង់អគាររដ្ឋបាល និងការកែលម្អ (កំពុងដំណើរការ) | ចំណាយលើការសាងសង់អគារ និង សំណង់ផ្សេងៗទៀត និង ចំណាយលើការកែលម្អអគារ ដែលរដ្ឋជាកម្មសិទ្ធិករ។ (កំពុងដំណើរការ) | ✓ | ✓ | ✓ | ✓ |
| | | 23031 | សំណង់អគាររដ្ឋបាល (កំពុងដំណើរការ) | ចំណាយលើការសាងសង់អគាររដ្ឋបាលសម្រាប់បម្រើឲ្យការងាររដ្ឋាភិបាល។ (កំពុងដំណើរការ) | ✓ | ✓ | ✓ | ✓ |
| | | 23032 | ការកែលម្អអគាររដ្ឋបាល (កំពុងដំណើរការ) | ចំណាយលើការរៀបចំកែលម្អអគារក្នុងទ្រង់ទ្រាយធំ ហើយការងារនេះបានធ្វើឲ្យកើនឡើងនូវតំលៃអគារនោះ ដូចជា ការជួសជុលធំបូល ការជួសជុលរួមនៃប្រព័ន្ធអគ្គិសនី។ល។ រីឯការជួសជុលតូចតាចដូចជា ការបន្ថែមផ្ទាំងគំនូរ ការជួសជុលបង្អួច ការលាបពណ៌ ត្រូវបញ្ចូលក្នុងថ្នាក់ ៦ (ចំណាយចរន្ត)។ (កំពុងដំណើរការ) | ✓ | ✓ | ✓ | ✓ |

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥... សហវ.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 23038 | សំណង់ផ្សេងៗ (កំពុងដំណើរការ) | ចំណាយលើការសាងសង់ផ្សេងៗ ដែលមិនមែនជាអគារ ដូចជាវិមានឯករាជ្យ ជញ្ជាំងព្រះបរមរាជវាំង។ (កំពុងដំណើរការ) | ✓ | ✓ | ✓ | ✓ |
| | 2304 | | **ហេដ្ឋារចនាសម្ព័ន្ធ (កំពុងដំណើរការ)** | ចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23041 | ផ្លូវថ្នល់ (កំពុងដំណើរការ) | ចំណាយលើការសាងសង់ផ្លូវថ្នល់ ដូចជា ផ្លូវឡាន ផ្លូវថ្មើរជើង ស្ពាន ការដាក់ប្រព័ន្ធលូ ដែលពាក់ព័ន្ធនឹងការសាងសង់ ផ្លូវថ្នល់ ... (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23042 | ធារាសាស្ត្រ (កំពុងដំណើរការ) | ចំណាយលើការសាងសង់ប្រព័ន្ធធារាសាស្ត្រ ដូចជា ផ្លូវទឹក ទំនប់ ព្រែកជីក ការជីកស្រះ ... (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23043 | អាយស្ម័យយាន (កំពុងដំណើរការ) | ចំណាយលើការសាងសង់អាយស្ម័យយាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឲ្យអាយស្ម័យយាន ដូចជាផ្លូវដែក ព្រែកជីកសម្រាប់រថភ្លើងឆ្លងកាត់ ... (កំពុងដំណើរការ)។ | ✓ | | | |
| | | 23044 | អាកាសយានដ្ឋាន (កំពុងដំណើរការ) | ចំណាយលើការសាងសង់អាកាសយានដ្ឋាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឲ្យអាកាសយានដ្ឋាន ដូចជា កន្លែងចុះចតយន្តហោះ ... (កំពុងដំណើរការ)។ | ✓ | | | |
| | | 23045 | ទូរគមនាគមន៍ (កំពុងដំណើរការ) | ចំណាយលើការតំលើងប្រព័ន្ធទូរគមនាគមន៍ ដូចជា ខ្សែទូរគមនាគមន៍ អង់តែនសម្រាប់ទទួលផ្កាយរណប ខ្សែកាប ... (កំពុងដំណើរការ)។ | ✓ | | | |
| | | 23046 | អគ្គិសនី (កំពុងដំណើរការ) | ចំណាយលើការសាងសង់រោងចក្រអគ្គិសនី និងចំណាយផ្សេងៗទៀតដើម្បីបម្រើឲ្យការងារអគ្គិសនី ដូចជាខ្សែភ្លើងទប់អគ្គិសនី កំលាំងខ្ពស់ (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | |
| | | 23047 | បណ្តាញបង្ហូរទឹក និងអនាម័យ (កំពុងដំណើរការ) | ចំណាយលើការសាងសង់បណ្តាញបង្ហូរទឹកដូចជា ការដាក់ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ការជីកអាងស្តុកទឹកសម្រាប់ការធ្វើ បន្សុតទឹកកខ្វក់ (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | | 23048 | ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (កំពុងដំណើរការ) | ចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ ដូចជាពហុកីឡដ្ឋាន មជ្ឈមណ្ឌលកំសាន្ត លូទឹកស្អុយ អណ្តូង និងកន្លែងធ្វើអាជីវកម្មស្រទាប់រ៉ែនៅក្រោមដី (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | ✓ |
| | 2305 | | **ឋបនកម្ម បច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ (កំពុងដំណើរការ)** | ចំណាយលើឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ ដែលត្រូវបានចាត់ថ្នាក់នៅក្នុងចំណាយជាមូលធន (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | |
| | | 23051 | ឋបនកម្ម បច្ចេកទេស (កំពុងដំណើរការ) | ចំណាយលើឋបនកម្មបច្ចេកទេស ដូចជាកន្លែងសម្រាប់បំពង់បូមទឹកឧទ្ធតអគ្គីភ័យ និងសម្ភារៈរបស់វា និងយានដ្ឋាន (កំពុងដំណើរការ)។ | ✓ | ✓ | ✓ | |

## ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ ក.ក្ត. ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| | | 23052 | សម្ភារៈ ( កំពុងដំណើរការ ) | ចំណាយលើការទិញសម្ភារៈផ្សេងៗ ដូចជាសម្ភារៈសម្រាប់ធ្វើរោងទំនិញ រោងជាង និងយានដ្ឋាន សម្ភារៈអគ្គីភ័យ សម្ភារៈ ផ្លូវថ្នល់ និងសម្ភារៈការងារសាធារណៈ ដែលទំហំទឹកប្រាក់ចំណាយនោះត្រូវបានចាត់ជាចំណាយមូលធន ( កំពុងដំណើរការ )។ | ✓ | ✓ | ✓ | |
| | | 23053 | គ្រឿងឧបករណ៍ ( ហត្ថូបករណ៍ ) ( កំពុងដំណើរការ ) | ចំណាយលើគ្រឿងឧបករណ៍ធំ ដែលមានឯកតាខ្ពស់ជៀបទៅនឹងដែនកំណត់អចលកម្ម ( កំពុងដំណើរការ )។ | ✓ | ✓ | ✓ | |
| | | 23058 | ផ្សេងៗ ( កំពុងដំណើរការ ) | ចំណាយលើបបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ផ្សេងទៀត ក្រៅពីអនុគណនីខាងលើ ( កំពុងដំណើរការ )។ | ✓ | ✓ | ✓ | |
| 26 | | | **ភារវិនិយោគ** | ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា ចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន... | ✓ | | | |
| | 2601 | | ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា | ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា | ✓ | | | |
| | | 26011 | ការវិនិយោគក្នុងញាតិសម្ព័ន្ធ | ជាការវិនិយោគមួយដែលធ្វើឡើងដោយអង្គភាពមួយទៅលើអង្គភាពមួយទៀតដែលអ្នក វិនិយោគមានឥទ្ធិពលសំខាន់ និង មិនមែនជាអង្គភាពគ្រប់គ្រងរួម និង មិនមែនជាភាគកម្មនៅ ក្នុងក្រុមហ៊ុនរួមទុន។ | ✓ | | | |
| | | 26012 | ការវិនិយោគទុនរួមគ្នា | រៀបរាប់អំពីការវិនិយោគមួយដែលត្រូវបានចងដោយកិច្ចសន្យាដែលភាគីពីរ ឬ ច្រើន បានប្តេជ្ញាអនុវត្តសកម្មភាពដែលជាកម្មវត្ថុនៃការគ្រប់គ្រងរួម។ | ✓ | | | |
| | | 26013 | ការវិនិយោគក្នុងសហគ្រាសសាធារណៈ | ការវិនិយោគនៅក្នុងសហគ្រាសសាធារណៈជាទំរង់នៃភាគហ៊ុនត្រូវបានគេពន្យល់ថា ជាការវិនិយោគដែលរដ្ឋាភិបាលដាក់ទុនវិនិយោគដើម្បីទិញចំណែកខ្លះនៃភាគកម្មនៅក្នុងសហគ្រាសសាធារណៈ។ ឧទាហរណ៍ ការវិនិយោគរបស់រាជរដ្ឋាភិបាលនៅក្នុងទូរគមនាគមន៍កម្ពុជា ( Telecom Cambodia ) ជាដើម ។ល។ | ✓ | | | |
| | 2602 | | ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនញាតិសម្ព័ន្ធនិងក្រុមហ៊ុនដាក់ទុនរួមគ្នា | ជាចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន។ | ✓ | | | |
| | | 26021 | ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនញាតិសម្ព័ន្ធ | ជាចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។ | ✓ | | | |
| | | 26022 | ការបែងចែកប្រាក់ចំណេញឬខាតនៃក្រុមហ៊ុនដាក់ទុនរួមគ្នា | ជាចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងក្រុមហ៊ុនក្រុមហ៊ុនរួមទុន។ | ✓ | | | |
| | | 26023 | ការបែងចែកប្រាក់ចំណេញឬខាតនៃសហគ្រាសសាធារណៈ | ជាចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងសហគ្រាសសាធារណៈ។ | ✓ | | | |

## ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ ២០១៣

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់ស្រុក | ថ្នាក់ឃុំ |
|---|---|---|---|---|---|---|---|---|
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | អចលកម្មហិរញ្ញវត្ថុដទៃទៀតរួមមាន ១-តំលៃទទួលបានក្នុងក្របខ័ណ្ឌនៃការចល័តថវិកាជាមួយនឹងតំលៃដែលទទួលបាន ដោយការឲ្យ (ភាគហ៊ុន សញ្ញាប័ណ្ណ ) ២-កម្ចីដែលជាមូលនិធិដែលត្រូវបង្វែរទៅតតីយជន អាស្រ័យដោយបទបញ្ញត្តិ នៃកិច្ចសន្យាដែលអនុញ្ញតដោយអត្ថបទច្បាប់ ឬ បទបញ្ជា ដែលរដ្ឋបានបង្វែរទៅឲ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលក្នុងការប្រើ ប្រាស់ជាមធ្យោបាយទូទាត់ក្នុងរយៈពេលមួយ កំណត់ ៣-ប្រាក់បញ្ញើនិងកិច្ចសន្យាធានារ៉ាប់រង។ មាតិកាថវិកាខ្ទង់បំរុង ប្រើប្រាស់គណនីជាមូលដ្ឋាន ២៧១។ គណនី ២៧១ ត្រូវបានកត់ត្រាខាងឥណពន្ធទឹកប្រាក់ឲ្យខ្ចី និងកត់ត្រាខាងឥណទានទឹកប្រាក់ត្រូវសងជាមូលធននៃកម្ចី។ | ✓ | | | |
| | 2701 | | ការឲ្យខ្ចី | គណនីមូលធនឲ្យខ្ចីត្រូវកត់ត្រាខាងឥណពន្ធ រីឯទឹកប្រាក់បានទទួលពីការខ្ចីត្រូវកត់ត្រាខាងឥណទាន។ ចំណូលពីការប្រាក់ឲ្យខ្ចីត្រូវកត់ត្រាក្នុងអនុគណនី ៧៦០១១។ | ✓ | | | |
| | | 27011 | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ។ | ✓ | | | |
| | | 27012 | ការឲ្យខ្ចី ទៅសហគ្រាសឯកជន | ការឲ្យខ្ចី ទៅសហគ្រាសឯកជន។ | ✓ | | | |
| | | 27013 | ការឲ្យខ្ចី ទៅអង្គការមិនមែនរដ្ឋាភិបាល | ការឲ្យខ្ចី ទៅអង្គការមិនមែនរដ្ឋាភិបាល។ | ✓ | | | |
| | | 27018 | ការឲ្យខ្ចីផ្សេងៗ | ការឲ្យខ្ចីផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ | ✓ | | | |
| | 2702 | | អចលកម្មហិរញ្ញវត្ថុផ្សេងៗទៀត | អចលកម្មហិរញ្ញវត្ថុផ្សេងៗទៀត | ✓ | | | |
| | | 27022 | មូលប័ត្រ | សំដៅដល់មូលប័ត្រដែលរួមបញ្ចូលនូវឧបករណ៍បំណុល ( សញ្ញាប័ណ្ណ ) និងឧបករណ៍មូលធន ( ភាគហ៊ុន ) | ✓ | | | |
| | | 27028 | ផ្សេងៗ | ជាទ្រព្យសកម្មហិរញ្ញវត្ថុដទៃផ្សេងទៀតក្រៅពីការឲ្យខ្ចី និងមូលប័ត្រ | ✓ | | | |
| | | | **ក្រុមទី ២ : ចំណាយតាមដីកា ( ប្រភេទទី៣ )** | ចំណាយមិនឆ្លងកាត់សាច់ប្រាក់ គឺជាការបង្វែរ ឬ ការផ្ទេរនូវសមិទ្ធិផលដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍។ | ✓ | ✓ | ✓ | ✓ |
| | | | **ប្រភេទទី ៣ : ចំណាយតាមដីកា** | ចំណាយមិនឆ្លងកាត់សាច់ប្រាក់ គឺជាការបង្វែរ ឬ ការផ្ទេរនូវសមិទ្ធិផលដែលអនុវត្តដោយដៃគូអភិវឌ្ឍន៍។ | ✓ | ✓ | ✓ | ✓ |

៥៨